# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

**ព្រឹទ្ធសភា**
**អគ្គលេខាធិការដ្ឋាន**
លេខ ០៥៣/០៤២៤អ.ពស.នណ.និ.ប

# លិខិតបញ្ជូន

គោរពជូន: - គណៈកម្មការជំនាញទាំង១០ព្រឹទ្ធសភា
- អគ្គនាយកដ្ឋានទាំង៥
- នាយកដ្ឋានគ្រប់គ្រងបុគ្គលិក

| ល.រ | កម្មវត្ថុលិខិត | ចំនួន | សេចក្តីផ្សេងៗ |
|---|---|---|---|
| ០១ | របាយការណ៍ស្តីពីវឌ្ឍនភាពការងារប្រចាំខែកុម្ភៈ ឆ្នាំ២០២៤ និងលើកទិសដៅការងារបន្តរបស់ក្រសួងមុខងារសាធារណៈ។ (ច្បាប់ថតចម្លង) | ០១ច្បាប់ | "ដើម្បីជូនជ្រាបជាព័ត៌មាន" |

ថ្ងៃព្រហស្បតិ៍ ២រោច ខែចេត្រ ឆ្នាំរោង ឆស័ក ព.ស២៥៦៧
រាជធានីភ្នំពេញ ថ្ងៃទី ២៥ ខែមេសា ឆ្នាំ២០២៤

**ជ.អគ្គលេខាធិការ**
**អគ្គលេខាធិការរង**

**ខេង សិទ្ធិគុណា**

វិមានរដ្ឋចំការមន មហាវិថីព្រះនរោត្តម រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ: (855 23) 211 441, 211 442, 211 443 ទូរសារ: (855 23) 211 446, E-mail: secretariat@senate.gov.kh

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងមុខងារសាធារណៈ

លេខ : ៨៣៤/២៤ មស.ឌកស

ថ្ងៃ អង្គារ ១០កើត ខែ ផល្គុន ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧
រាជធានីភ្នំពេញ ថ្ងៃទី ១៩ ខែ មីនា ឆ្នាំ២០២៤

# លិខិតផ្ញើ

**សូមគោរពជូន**
**ឯកឧត្តមអគ្គលេខាធិការ នៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា**

| ល.រ | បរិយាយ | ចំនួន | សេចក្ដីផ្សេងៗ |
|---|---|---|---|
| ១ | របាយការណ៍ស្ដីពីវឌ្ឍនភាពការងារប្រចាំខែកុម្ភៈ ឆ្នាំ២០២៤ និង លើកទិសដៅការងារបន្តរបស់ក្រសួងមុខងារសាធារណៈ | ០១ច្បាប់ | "ដើម្បីជូនជ្រាប" |
| | **សរុបចំនួន** | **០១ច្បាប់** | |

សូម **ឯកឧត្តម** មេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់ពីខ្ញុំបាទ។

**ជ.រដ្ឋមន្ត្រី**
**អគ្គលេខាធិការ**
**អគ្គលេខាធិការដ្ឋានក្រសួងមុខងារសាធារណៈ**

**ហាស់ ប៊ុនថ្លន**

ផ្លូវវត្តអង្គតាមិញ ភូមិគោកចំបក់ សង្កាត់ចោមចៅ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ/ទូរសារ : +៨៥៥-២៣-៨៦៦៥០១/+៨៥៥-២៣-៨៦៦៥០៥ | គេហទំព័រ : http://www.mcs.gov.kh

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងមុខងារសាធារណៈ**
លេខ៖ ៧១៣/២៤ មស.របក

# របាយការណ៍
# ស្តីពី
# វឌ្ឍនភាពការងារប្រចាំខែកុម្ភៈ ឆ្នាំ២០២៤
# និងលើកទិសដៅការងារបន្តរបស់ក្រសួងមុខងារសាធារណៈ

អនុលោមតាមគោលនយោបាយ របស់រាជរដ្ឋាភិបាលកម្ពុជា នៅក្នុងនីតិកាលទី៧ នៃរដ្ឋសភា ក្រសួងមុខងារសាធារណៈ បានអនុវត្តតួនាទី និងភារកិច្ចយ៉ាងសកម្ម ដើម្បីរួមចំណែកអនុវត្តយុទ្ធសាស្ត្របញ្ចកោណ ដំណាក់កាលទី១ របស់រាជរដ្ឋាភិបាល ដែលឆ្លើយតបទៅនឹងមុំប្រាំសំខាន់ គឺ (១)ការពង្រឹង និងការកែទម្រង់ស្ថាប័ន (២)ការលើកកម្ពស់សមត្ថភាពធនធានមនុស្ស និងការពង្រឹងប្រសិទ្ធភាពនៃការអនុវត្តការងារ (៣)ការលើកកម្ពស់ និងការពង្រឹងភាពស្អាតស្អំនៅក្នុងរដ្ឋបាលសាធារណៈ (៤)ការលើកកម្ពស់ និងការពង្រឹងប្រសិទ្ធភាពនៃច្បាប់ និងប្រព័ន្ធយុត្តិធម៌ និង(៥)ការពង្រឹងអភិបាលកិច្ចវិស័យឯកជន និងធុរកិច្ច។ នៅក្នុងរយៈពេល១ខែ នៃខែកុម្ភៈនេះ ក្រសួងមុខងារសាធារណៈ សម្រេចបានសមិទ្ធផលការងារសំខាន់ៗ ដូចខាងក្រោម ៖

## ១ ការពង្រឹង និងការកែទម្រង់ស្ថាប័ន

### ១.១ ការអនុវត្តការងាររបស់ថ្នាក់ដឹកនាំក្រសួង

ថ្នាក់ដឹកនាំក្រសួងបានអញ្ជើញចូលរួមកិច្ចប្រជុំ ការងារសង្គម និងពិធីផ្សេងៗ រួមមាន (១)អង្គប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី (២)ចូលរួម និងដឹកនាំកិច្ចប្រជុំអន្តរក្រសួង (៣)ក្រុមការងាររាជរដ្ឋាភិបាលចុះមូលដ្ឋានតាមបណ្តាខេត្តនានាទូទាំងប្រទេស ជាពិសេសខេត្តកំពង់ស្ពឺ និង (៤)ចូលរួមកម្មវិធីនានាតាមការអញ្ជើញរបស់គណៈកម្មាធិការរៀបចំបុណ្យជាតិ អន្តរជាតិ និងក្រសួង ស្ថាប័ននានា។

### ១.២ ការងារអគ្គលេខាធិការដ្ឋាននៃក្រសួងមុខងារសាធារណៈ

ការងារផែនការ៖

- បានបញ្ចប់ការរៀបចំផែនការប្រតិបត្តិឆ្នាំ២០២៤ និងបានផ្សព្វផ្សាយជូនអង្គភាពក្រោមឱវាទក្រសួងមុខងារសាធារណៈទាំងអស់ ដើម្បីយកទៅអនុវត្ត
- បានបូកសរុបរបាយការណ៍វឌ្ឍនភាពការងារប្រចាំខែមករា ឆ្នាំ២០២៤ របស់ក្រសួងមុខងារសាធារណៈ ដើម្បីផ្ញើជូនទីស្តីការគណៈរដ្ឋមន្ត្រីតាមការកំណត់
- បានត្រៀមសម្រាប់ការរៀបចំសន្និបាតបូកសរុបលទ្ធផលការងារឆ្នាំ២០២៣ និងលើកទិសដៅការងារឆ្នាំ២០២៤។ សម្រាប់កិច្ចការនេះ អគ្គលេខាធិការដ្ឋានបានរៀបចំសម្របសម្រួលជាមួយមន្ទីរមុខងារសាធារណៈទាំង ២៥រាជធានីខេត្ត ដើម្បីរៀបចំខ្លឹមសារចូលរួមសន្និបាត ដោយផ្តោតលើបញ្ហាប្រឈម និងទិសដៅការងារពាក់ព័ន្ធនឹងការសម្រួលរចនាសម្ព័ន្ធក្រសួង ទំនាក់ទំនងនឹងក្រសួងមុខងារសាធារណៈ និងទំនាក់ទំនងនឹងរដ្ឋបាលថ្នាក់ក្រោមជាតិ។ ជាមួយគ្នានេះដែរ នាយកដ្ឋានផែនការក៏បាន រៀបចំជាសេចក្តីជូន ដំណឹង ភ្ជាប់ជាមួយទម្រង់របាយការណ៍

ដើម្បីអង្គភាពពាក់ព័ន្ធរៀបចំរបាយការណ៍ត្រៀមផ្សព្វផ្សាយ ក្នុងកម្មវិធីសន្និបាតបូកសរុបលទ្ធផលការងារឆ្នាំ២០២៣ និងលើកទិសដៅការងារឆ្នាំ២០២៤ នេះផងដែរ

- បានបូកសរុបរបាយការណ៍វឌ្ឍនភាពការងារប្រចាំខែកុម្ភៈ ឆ្នាំ២០២៤ របស់ក្រសួងមុខងារសាធារណៈ ដើម្បីជាមូលដ្ឋាននៃការតាមដានត្រួតពិនិត្យ ផ្ញើជូនទីស្តីការគណៈរដ្ឋមន្ត្រីតាមការកំណត់ និងរបស់មន្ទីរមុខងារសាធារណៈរាជធានី ខេត្ត គោរពជូនឯកឧត្តមរដ្ឋមន្ត្រី។

ការងារធនធានមនុស្ស៖

- ក្រសួងមុខងារសាធារណៈមានមន្ត្រីរាជការសរុបចំនួន ១៣៦៣នាក់/ស្ត្រី ៤៦៥នាក់ ថ្នាក់ជាតិសរុបចំនួន ៨៥៨នាក់/ស្ត្រី ២៦៩នាក់ ថ្នាក់ក្រោមជាតិសរុបចំនួន ៥០៥នាក់/ស្ត្រី ១៩៦នាក់ និងមន្ត្រីកិច្ចសន្យាសរុបចំនួន ៣៦៤នាក់/ស្ត្រី ១៨៣នាក់ ថ្នាក់ជាតិសរុបចំនួន ២៤៥នាក់/ស្ត្រី ១២១នាក់ ថ្នាក់ក្រោមជាតិសរុបចំនួន ១១៩នាក់/ស្ត្រី ៦២នាក់
- បានរៀនចំបម្រែបម្រួលស្ថានភាពរដ្ឋបាលជូនមន្ត្រីរាជការថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិចំនួន១៣នាក់/ស្ត្រី០២នាក់
- បានធ្វើសេចក្តីសម្រេចជូនមន្ត្រីរាជការ ចំនួន ០១រូប ឱ្យទំនេរពីមុខងារ ដើម្បីទៅបន្តការសិក្សាថ្នាក់អនុបណ្ឌិតនៅប្រទេសអូស្ត្រាលីដោយរក្សាបៀវត្ស អតីតភាពការងារ និងមុខតំណែងក្នុងអង្គភាពដើម
- បានរៀបចំ និងសម្របសម្រួលការធ្វើបទបង្ហាញស្តីពី តួនាទី ភារកិច្ចក្រសួងមុខងារសាធារណៈ ក្នុងការងារកែទម្រង់រដ្ឋបាលសាធារណៈ ដល់សមាជិក សមាជិកា អ្នកស្រាវជ្រាវ និងកម្មសិក្សាការីរបស់សមាគមសាលាត្រាជូចូលទស្សនកិច្ចសិក្សានៅក្រសួងមុខងារសាធារណៈ ចំនួន ៣២ នាក់/ស្ត្រី ០៨នាក់
- បានប្រមូល និងបូកសរុបបញ្ជីវត្តមានរបស់មន្ត្រីរាជការសម្រាប់ ខែកុម្ភៈ ឆ្នាំ២០២៤ ចំនួន ៤២ អង្គភាព ចំណុះទីស្តីការក្រសួងមុខងារសាធារណៈ ហើយមន្ត្រីមកបម្រើការងារមានចំនួន ៨៨.២% នៃចំនួនមន្ត្រីសរុប ៦៧៨ នាក់/ស្ត្រី ២១៣នាក់ អវត្តមាន មានច្បាប់ ៤.២% និងអវត្តមាន ឥតច្បាប់ ៧.៥២%។

ការងារហិរញ្ញវត្ថុ

- បានគាំទ្រផ្នែកហិរញ្ញវត្ថុ និងផ្គត់ផ្គង់ដល់កិច្ចដំណើរការប្រឡងប្រជែងជ្រើសរើសគ្រូបង្រៀនឯកទេសអប់រំកាយ និងកីឡាឱ្យគ្រូកីឡា។
- ប្រកាសអន្តរក្រសួងស្តីពីការបង្កើតអគ្គលេខាធិការដ្ឋានកែទម្រង់រដ្ឋបាលសាធារណៈ ជាអង្គភាពថវិកា អាណាប័កផ្ទេរសិទ្ធពេញលេញត្រូវបានអនុម័ត
- ពង្រឹងការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ និងបញ្ជីសារពើភណ្ឌដោយបានរៀបចំតារាងកើនឡើង-ថយចុះសម្រាប់ ឆ្នាំ២០២៣
- សេចក្តីសម្រេចកែសម្រួលសមាសភាពទ្រព្យរដ្ឋ របស់មន្ទីរម.សខេត្តកំពង់ស្ពឺនិងខេត្តព្រៃវែងរួចរាល់ត្រូវបានចុះហត្ថលេខា
- សេចក្តីសម្រេចបង្កើតគណៈកម្មការបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋ របស់ក្រសួងត្រូវបានដាក់ជូនថ្នាក់ដឹកនាំពិនិត្យនិងចុះហត្ថលេខា
- ការគ្រោងចំណាយ និងសំណើសុំថវិកាសម្រាប់អនុវត្តកម្មវិធីខួបលើកទី១១៣ ទិវាសិទ្ធិនារី ៨មីនា ឆ្នាំ២០២៤ ត្រូវបានរៀបចំសុំការពិនិត្យសម្រេច
- ការគ្រោងចំណាយ និងសំណើសុំថវិកាសម្រាប់ការរៀបចំសន្និបាតក្រសួង និងសំណើសុំថវិកាសម្រាប់អនុវត្តកម្មវិធីខួបលើកទី១១៣ ទិវាសិទ្ធិនារី ៨មីនា ឆ្នាំ២០២៤ ត្រូវបានរៀបចំស្នើសុំការពិនិត្យសម្រេច

**ការងាររដ្ឋបាល៖**

- បន្តពង្រឹងការគ្រប់គ្រងចរន្តឯកសារ ដែលមាននាយកដ្ឋានរដ្ឋបាលជាច្រកចេញចូលតែមួយ ដោយបានចុះលេខលិខិតចូលចំនួន៧១៣លេខ ចេញ ២៩៤លេខ (បេសកកម្ម ១៣លេខ) បញ្ចូលឯកសារក្នុងប្រព័ន្ធចរន្តឯកសាររដ្ឋបាលបានចំនួន ៣៥៣ច្បាប់ និងបញ្ជូនចេញចំនួន៤៨៧លិខិត
- បានជួយរៀបចំកន្លែងប្រជុំចំនួន៦០លើក សរុបសមាជិក២៧៨៨នាក់៖ រួមមានប្រជុំផ្ទៃក្នុងក្រសួង អន្តរក្រសួង អន្តរក្រសួងចង្អៀត កម្រិតអគ្គនាយកដ្ឋាន/អគ្គលេខាធិការដ្ឋាន/នាយកដ្ឋាន ក្រុមការងារ និងអន្តរជាតិ
- បានរៀបចំនិងពង្រឹងសន្តិសុខ សណ្តាប់ធ្នាប់ ការរក្សាអនាម័យ និងបរិស្ថានក្រសួង

**ការងារនីតិកម្ម**

- បានពិនិត្យកែសម្រួលអនុក្រឹត្យចំនួន ៥ (អាកាសចរស៊ីវិល អប់រំ សុខាភិបាល ការជូនមេដាយការងារ ការទទួលស្គាល់ជ័យលាភីអង្គភាពផ្តល់សេវាសាធារណៈគំរូក្នុងវិស័យអប់រំនិងវិស័យសុខាភិបាល)
- បានពិនិត្យកែសម្រួលប្រកាសអន្តរក្រសួងចំនួន២( សុខាភិបាល អប់រំ)
- បានរៀបចំលិខិតឆ្លើយតបសំណើរបស់រដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិល និងរដ្ឋលេខាធិការដ្ឋានកិច្ចការព្រំដែន

**ការងារផ្សព្វផ្សាយនិងទំនាក់ទំនងសាធារណៈ**

- លទ្ធផលនៃការផ្សព្វផ្សាយព័ត៌មានតាមរយៈគេហទំព័រក្រសួង និងបណ្តាញសង្គមថ្មី Website post ចំនួន ៩១ លើក Facebook មាន follower សរុប ២៦០ ១៧១នាក់ Tik Tok មាន follower សរុប ៧៣៦នាក់ Youtube មាន subscriber សរុប ៩០៩នាក់ MCS Telegram Channel post មាន subscriber សរុប ៩ ៩៧៩នាក់
- លើការផ្សាយព័ត៌មាននានាសម្រាប់ខែកុម្ភៈនៅលើទំព័រ(Facebook) ផ្លូវការរបស់ក្រសួង ចំនួន៨៤លើក គឺទទួលបានការចុច (Likes) ចំនួន៧៩,៨៧៧នាក់ និងការចូលទៅផ្តល់យោបល់ (Comments) ចំនួន ២៣,៨៣០នាក់ និងការចែករំលែក (Shares) ចំនួន២៣,១៨៩នាក់
- បានរៀបចំក្រុមការងារចូលរួមយកព័ត៌មានកិច្ចប្រជុំថ្នាក់ដឹកនាំ និងកម្មវិធីផ្សេងៗរបស់ក្រសួង សម្រាប់ផ្សព្វផ្សាយសរុបចំនួន ២៦លើក ផ្សព្វផ្សាយជាសាធារណៈចំនួន ៩លើក និងផ្សព្វផ្សាយផ្ទៃក្នុងចំនួន ១៧លើក
- បានការតាមដាននិងសង្ខេបព័ត៌មានប្រចាំថ្ងៃ ពីស្ថាប័នសារព័ត៌មាននានាពាក់ព័ន្ធនឹងការងារមុខងារសាធារណៈ រដ្ឋបាលសាធារណៈ និងរាជរដ្ឋាភិបាល រួមទាំងព្រឹត្តិការណ៍ជាតិនិងអន្តរជាតិ សរុបចំនួន ១,៣៣៩មាតិការឿង
- បានសម្របសម្រួលរៀបចំសន្និសីទសារព័ត៌មាន ១លើក និងកិច្ចសម្ភាសន៍ជាមួយអ្នកសារព័ត៌មាន ៤លើក លើការប្រឡងប្រជែងជ្រើសរើសគ្រូបង្រៀន ឯកទេសអប់រំកាយ និងកីឡា និងបានផ្សព្វផ្សាយព័ត៌មានពាក់ព័ន្ធនឹងការជ្រើសរើសគ្រូអនុវិទ្យាល័យនិងផលិតវីដេអូពីរបៀបចុះឈ្មោះប្រឡង
- បានរៀបចំផលិតវីដេអូស្ដីពីអង្គភាពសាធារណៈគំរូឆ្លាក់សម្រាប់ពិធីប្រកាសជ័យលាភីថ្ងៃទី២១ និង២២ ខែកុម្ភៈ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់សម្ដេចធិបតីនាយករដ្ឋមន្ត្រី
- បានផលិតផ្សព្វផ្សាយវីដេអូចំនួន៧ រួមជាមួយនឹងការរៀបចំរចនាផូស្ទ័រចំនួន៧០ និងសម្របសម្រួលអ្នកសង្កេតការណ៍សាធារណជន តំណាងសាកលវិទ្យាល័យ ស.ស.យ.ក. និងសារព័ត៌មានចំនួនប្រមាណ១៦១នាក់ ដើម្បីចូលរួមជាសាក្សីនិងសង្កេត ពាក់ព័ន្ធនឹងកិច្ចការងារកំណែទម្រង់និងប្រឡងជ្រើសរើសគ្រូបង្រៀនឯកទេសអប់រំកាយនិងកីឡានិងគ្រូបង្រៀនអនុវិទ្យាល័យ ដែលបានបង្ហាញពីការជ្រើសរើសឈរលើគោលការណ៍គុណាធិបតេយ្យ តម្លាភាព យុត្តិធម៌ បរិយាបន្ន និងប្រសិទ្ធភាព។

## ១.៣ ភារខារអគ្គនាយកដ្ឋានគ្រប់គ្រងមុខងារសាធារណៈ

ការងារក្របខណ្ឌ

- បានសហការក្នុងដំណើរការប្រឡងប្រជែងជ្រើសរើសគ្រូបង្រៀនឯកទេសអប់រំកាយ និងកីឡាចំនួន១០០កន្លែង កាលថ្ងៃអាទិត្យ ទី២៨ ខែមករា ឆ្នាំ២០២៤ នៅមណ្ឌលប្រឡងសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច និងវិញ្ញាសាអនុវត្តន៍កីឡា ចាប់ពីថ្ងៃទី២៩ ខែមករា រហូតដល់ថ្ងៃទី៥ ខែកុម្ភៈ ឆ្នាំ២០២៤ នៅមណ្ឌលប្រឡងវិទ្យាស្ថានជាតិអប់រំកាយ និងកីឡា ក្នុងនោះបេក្ខជនជាប់ជាស្ថាពរកម្រិតសម្រាប់បណ្តុះបណ្តាល១២+២ ចំនួន ៧៥នាក់/ស្ត្រី ៧នាក់ និង១២+៤ចំនួន ២៥នាក់/ស្ត្រី ១នាក់
- បានបង្កើតអនុគណៈកម្មការពិនិត្យ និងផ្ទៀងផ្ទាត់សន្លឹកកិច្ចការប្រឡងប្រជែងជ្រើសរើសគ្រូបង្រៀនឯកទេសអប់រំកាយ និងកីឡា ឱ្យចូលបម្រើការងារក្នុងក្របខណ្ឌក្រសួងអប់រំ យុវជន និងកីឡា
- បានរៀបចំកំណត់បង្ហាញរឿងករណីស្នើសុំក្របខណ្ឌពិសេស និងលិខិតឆ្លើយតបជូនក្រសួងអប់រំ យុវជន និងកីឡា លើសំណើសុំក្របខណ្ឌចំនួន០១នាក់ និងបញ្ចូលគ្រូជាប់កិច្ចសន្យាស្ម័គ្រចិត្តចំនួន១៧នាក់
- បានត្រួតពិនិត្យផ្នែករដ្ឋបាលលើសំណើសុំរបស់ក្រសួង ស្ថាប័ន ដើម្បីស្នើសុំការសម្រេចដ៏ខ្ពង់ខ្ពស់ពីប្រមុខរាជរដ្ឋាភិបាល និងផ្តល់ទិដ្ឋាការជូនក្រសួង ស្ថាប័ន ដូចខាងក្រោម៖

| ល.រ | បរិយាយ | ស្នើសុំការសម្រេច | | ផ្តល់ទិដ្ឋាការ | |
|---|---|---|---|---|---|
| | | សរុប | ស្ត្រី | សរុប | ស្ត្រី |
| ១ | ការបញ្ចូលបេក្ខជនជាប់បម្រុង | | | ១ | |
| ២ | ការផ្តល់ទិដ្ឋាការសលាកបត្រព័ត៌មាន | | | ១៧ | ៥ |
| ៣ | អត្តលេខមន្ត្រីថ្មី | | | ២៧ | ៧ |
| ៤ | ការផ្ទេរក្របខណ្ឌ | | | ២៩ | ៩ |
| ៥ | ការចូលនិវត្តន៍តាមអាយុកំណត់ | | | ៧ | ២ |
| ៦ | ការចូលនិវត្តន៍មុនអាយុ | ១៤ | ២ | ១៩ | ៧ |
| ៧ | ការផ្លាស់ប្តូរកន្លែងបម្រើការងារ | | | ៣ | |
| ៨ | ការរៀបចំ ប.ជ.ស (ក្រ.សង្គមកិច្ច) | | | ២៨ | ៦ |
| ៩ | ការប្រើប្រាស់មន្ត្រីជាប់កិច្ចសន្យា | | | ៣៦៥១ | |
| សរុប | | ១៤ | ២ | ៣៧៨២ | ៣៦ |

ការងារអាជីព

បានត្រួតពិនិត្យផ្នែករដ្ឋបាលលើសំណើសុំរបស់ក្រសួង ស្ថាប័ន ដើម្បីស្នើសុំការសម្រេចដ៏ខ្ពង់ខ្ពស់ពីប្រមុខរាជរដ្ឋាភិបាល ចំនួន១,៤៧៣ករណី និងផ្តល់ទិដ្ឋាការជូនក្រសួង ស្ថាប័នចំនួន៥៩៧ករណី ដូចខាងក្រោម៖

| ល.រ | បរិយាយ | សំណើសុំការសម្រេច | | ផ្តល់ទិដ្ឋាការ | |
|---|---|---|---|---|---|
| | | សរុប | ស្ត្រី | សរុប | ស្ត្រី |
| ១ | តាំងស៊ប់ក្នុងក្របខណ្ឌ | ១៤២៨ | ៧៤៨ | ០ | ០ |
| ២ | ដំឡើងថ្នាក់ និងឋានន្តរស័ក្តិតាមវេន | ០ | ០ | ០ | ០ |
| ៣ | ដំឡើងថ្នាក់ និងឋានន្តរស័ក្តិតាមសញ្ញាបត្រ | ២៣ | ៨ | ៨៣ | ១៦ |
| ៤ | ដំឡើងថ្នាក់កិត្តិយស | ៩ | ១ | ១០ | ២ |
| ៥ | និយ័តកម្មថ្នាក់ និងឋានន្តរស័ក្តិ | ០ | ០ | ០ | ០ |
| ៦ | រៀបប្រាក់បំណាច់មុខងារ | ០ | ០ | ២ | ១ |

| ល.រ | បរិយាយ | សំណើសុំការសម្រេច | | ផ្តល់ទិដ្ឋាការ | |
|---|---|---|---|---|---|
| | | សរុប | ស្ត្រី | សរុប | ស្ត្រី |
| ៧ | បញ្ចប់មុខតំណែង | ១ | ១ | ០ | ០ |
| ៨ | ស្ថិតនៅក្រៅក្របខណ្ឌដើម | ០ | ០ | ២ | ០ |
| ៩ | ស្ថិតក្នុងភាពទំនេរគ្មានបៀវត្ស | ៣ | ១ | ០ | ០ |
| ១០ | ចូលបម្រើការងារជាថ្មី | ០ | ០ | ០ | ០ |
| ១១ | ប្រាក់បំណាច់មន្ត្រីឧត្តមកាលយ | ០ | ០ | ២១៨ | ៧២ |
| ១២ | បន្តការសិក្សាដោយរក្សាទុកក្របខណ្ឌ | ០ | ០ | ០ | ០ |
| ១៣ | បច្ច័យនិច្ចកត្តប្រគេនព្រះសង្ឃ | ០ | ០ | ១៥ | ០ |
| ១៤ | កែតម្រូវថ្នាក់កំណើត | | | ១ | ១ |
| ១៥ | តែងតាំង | ៩ | ០ | ១៧៦ | ៥៤ |
| | សរុប | ១៤៧៣ | ៧៥៩ | ៥០៧ | ១៤៦ |

ការងារបៀវត្ស

ស្ថិតិមន្ត្រីនៅក្នុងតារាងទូទាត់បៀវត្សប្រចាំខែកុម្ភៈ ឆ្នាំ២០២៤ សរុប ២៣០,៩១៥នាក់ ស្មើនឹង១០០% (ស្ត្រី ៩៥,៩២៦នាក់) នៅថ្នាក់កណ្តាល ៥៣,៣០០នាក់ ស្មើនឹង ២៣,០៨% (ស្ត្រី ១៥,៦២០នាក់) និងថ្នាក់រាជធានី ខេត្ត ១៧៧,៦១៥នាក់ ស្មើនឹង ៧៦,៩២% (ស្ត្រី ៨០,៣០៦នាក់) ក្នុងនោះរួមមាន៖

- ចំនួនមន្ត្រីរាជការស៊ីវិលសរុប ២២២,០៩១នាក់ ស្មើនឹង១០០% (ស្ត្រី ៩៤,៤៦៤នាក់) នៅថ្នាក់កណ្តាល ៤៤,៥៥១នាក់ ស្មើនឹង ២០,០៦% (ស្ត្រី ១៤,១៩៨នាក់) និងថ្នាក់រាជធានី ខេត្ត ១៧៧,៥៤០នាក់ ស្មើនឹង ៧៩,៩៤% (ស្ត្រី ៨០,២៦៦នាក់)
- ក្របខណ្ឌ "ក" នៅថ្នាក់កណ្តាល ៣២,២១៨នាក់ ស្មើនឹង ៤៥,០២% (ស្ត្រី ៩,១១៥នាក់) និងថ្នាក់រាជធានី ខេត្ត ៣៩,៣៤១នាក់ ស្មើនឹង ៥៤,៩៨% (ស្ត្រី ១២,៦៨៧នាក់)
- ក្របខណ្ឌ "ខ" នៅថ្នាក់កណ្តាល ៨,៨៣២ នាក់ ស្មើនឹង ១១,៩៥% (ស្ត្រី ៣,៧៧៥នាក់) និងថ្នាក់រាជធានី ខេត្ត ៦៦,៩៥៨នាក់ ស្មើនឹង ៨៨,០៥% (ស្ត្រី ២៩,៦៩៤នាក់)
- ក្របខណ្ឌ "គ" នៅថ្នាក់កណ្តាល ៣,៥០១នាក់ ស្មើនឹង ៦,១៧% (ស្ត្រី ១,៣០៨នាក់) និងថ្នាក់រាជធានី ខេត្ត ៧១,២៤១នាក់ ស្មើនឹង ៩៣,៨៣% (ស្ត្រី ៣៧,៨៨៥នាក់)
- មន្ត្រីប្រភេទផ្សេងៗ (មន្ត្រីនយោបាយ ទីប្រឹក្សា ជំនួយការ...។ល។) នៅថ្នាក់កណ្តាល ៨,៧៤៩នាក់ ស្មើនឹង ៩៩,៥២% (ស្ត្រី ១,៤២២នាក់) និងថ្នាក់រាជធានី ខេត្ត ៧៥នាក់ ស្មើនឹង ០,៤៨% (ស្ត្រី ៤០នាក់)

បានបោះពុម្ពតារាងទូទាត់បៀវត្ស និងអាណត្តិបើកប្រាក់ សរុបចំនួន ៥៨ អង្គភាព រាជធានី ខេត្ត និងក្រសួង ស្ថាប័ន ថ្នាក់កណ្តាលចំនួន៣៣អង្គភាព និងរាជធានី ខេត្តចំនួន២៥ ក្នុងនោះរួមមាន៖

- កែតម្រូវស្ថានភាពរដ្ឋបាល និងគ្រួសាររបស់មន្ត្រីរាជការស៊ីវិលនៅក្នុងប្រព័ន្ធគ្រប់គ្រងមន្ត្រីរាជការស៊ីវិលតាមប្រព័ន្ធព័ត៌មានវិទ្យាចំនួន ១០,៤១៤ករណីថ្នាក់កណ្តាល ៥,៤៧៣ករណី ថ្នាក់រាជធានី ខេត្ត ៤,៩៤១ករណី
- ប្រើប្រាស់ឥណទានបៀវត្សចំនួន ៤១៨,០២៨,៦៥៣,៧៣៥រៀល ក្នុងនោះថ្នាក់រាជធានី ខេត្ត ចំនួន ៣០២,២៤៣,១៥៧,២៧១រៀល
- បានរៀបចំរបាយការណ៍បង្វែរប្រាក់បៀវត្សដែលបានបើកលើសសម្រាប់ខែមករា ឆ្នាំ២០២៤ សរុបចំនួន ៩០៦,៥០១,២២០ រៀល ក្នុងនោះថ្នាក់រាជធានី ខេត្ត ចំនួន ៥៥៦,២៥០,១៦៨រៀល។

ការងារវិមជ្ឈការ និងវិសហមជ្ឈការ

- បានចូលរួមជាគ្រូឧទ្ទេស សម្រាប់ការបណ្ដុះបណ្ដាលគោលការណ៍បែបបទ និងនីតិវិធីអនុវត្តមុខងារអប់រំ យុវជន និងកីឡា ដល់រដ្ឋបាលក្រុង ស្រុក ខណ្ឌ នៅសាលប្រជុំសាលាខេត្តកំពង់ចាម សៀមរាប និងបាត់ដំបង
- បានចងក្រងទិន្នន័យបុគ្គលិកអប់រំត្រូវសមាហរណកម្មទៅរដ្ឋបាលក្រុង ស្រុក ខណ្ឌ សរុបចំនួន ៥៧,៥៦៧នាក់ ក្នុងនោះបានរៀបចំផ្ទេររួចចំនួន ៥១,៤២៤នាក់
- បានចូលរួមកិច្ចប្រជុំពិភាក្សាលើ (១)ការផ្ទេរមុខងារក្នុងវិស័យអប់រំ យុវជន និងកីឡា ឱ្យទៅរដ្ឋបាលក្រុង ស្រុក ខណ្ឌ (២)ការផ្ទេរមុខងារក្នុងវិស័យអប់រំ យុវជន និងកីឡា ឱ្យទៅរដ្ឋបាលក្រុង ស្រុក ខណ្ឌ និងការត្រួតពិនិត្យស្ថានភាពបុគ្គលិកសុខាភិបាលថ្នាក់ក្រោមជាតិ និង (៣)ផ្ដល់ធាតុចូលសម្រាប់ការកសាងឯកសារទស្សនទានការធ្វើបច្ចុប្បន្នភាពវិស័យអប់រំ និងវិស័យសុខាភិបាល។

ការងារបណ្ណសារដ្ឋាន និងឯកសារ

បានធ្វើការបញ្ចូលទិន្នន័យស្ដីពីទីតាំងសលាកបត្រ និងឯកសារជារូបភាពដែលបានស្កេនចេញពីប្រអប់សលាកបត្រព័ត៌មានមន្ត្រីរាជការស៊ីវិល បានតម្កល់នៅការិយាល័យបណ្ណសារដ្ឋាន និងឯកសារ ចំនួន ៣,៥៩៣ករណី។

## ១.៤ ការងារអគ្គនាយកដ្ឋានប្រព័ន្ធគ្រប់គ្រងមន្ត្រីតាមឌីជីថល

- បានចូលរួមកិច្ចប្រជុំពិនិត្យ និងពិភាក្សាលើសេចក្ដីព្រាងអនុក្រឹត្យ ស្ដីពីគោលការណ៍នៃការបង្កើតអង្គភាពបរិវត្តកម្មឌីជីថលនៅតាមក្រសួង ស្ថាប័ន
- បានរៀបចំឯកសារស្នើសុំដាក់មន្ត្រីរាជការឱ្យស្ថិតនៅក្នុងភាពទំនេរគ្មានបៀវត្សចំនួន២នាក់ នៃអគ្គនាយកដ្ឋានប្រព័ន្ធគ្រប់គ្រងមន្ត្រីតាមឌីជីថល
- បានរៀបចំលិខិតឆ្លើយតបស្ដីពីសំណើសុំផ្ដល់គម្រោងកម្មវិធីនៃការកសាង សេចក្ដីព្រាងច្បាប់ និងលិខិតបទដ្ឋានគតិយុត្តិថ្មីៗ និងសេចក្ដីព្រាងវិសោធនកម្មច្បាប់ និងលិខិតបទដ្ឋានគតិយុត្តិផ្សេងៗទៀតសម្រាប់រយៈពេល ៥ឆ្នាំ(២០២៣-២០២៨)
- បានរៀបចំរបាយការណ៍ស្ដីពី លទ្ធផលកិច្ចប្រជុំតាមដានវឌ្ឍនភាពនៃការអនុវត្តគោលនយោបាយរដ្ឋាភិបាលឌីជីថលកម្ពុជា (២០២២-២០៣៥) និងការងារកសាងរដ្ឋាភិបាលឌីជីថល
- បានរៀបចំរបាយការណ៍ស្ដីពីកិច្ចសម្ភាសន៍ស្នើសុំទិន្នន័យ និងផ្ដល់គំរូដែលពាក់ព័ន្ធរចនាសម្ព័ន្ធគ្រប់គ្រងធនធានមនុស្សរបស់ក្រសួងអប់រំ យុវជន និងកីឡា និងក្រសួងសុខាភិបាល
- បានចូលរួមកិច្ចប្រជុំបន្តពិនិត្យ និងពិភាក្សាលើឯកសារទស្សនទានស្ដីពីការវិភាគមុខងារ និងរចនាសម្ព័ន្ធ ក្រោមអធិបតីភាពរបស់ **ឯកឧត្តម យក់ ប៊ុនណា** រដ្ឋលេខាធិការប្រចាំការ និងជាប្រធានអនុគណៈ កម្មាធិការប្រតិបត្តិនៃ គ.វ.រ
- បានបន្តសិក្សានិងរៀបអំពីស្តង់ដាសុវត្ថិភាពសម្រាប់យកមកប្រើប្រាស់ កំណត់សុវត្ថិភាពលើការអភិវឌ្ឍប្រព័ន្ធឌីជីថល និងការគ្រប់គ្រងហេដ្ឋារចនាសម្ព័ន្ធឌីជីថល
- បានសហការជាមួយនាយកដ្ឋានគ្រប់គ្រង និងអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធឌីជីថលក្នុងការតម្លើងម៉ាស៊ីនមេសម្រាប់ការងារ Data Warehouse
- បានសហការជាមួយនាយកដ្ឋានគ្រប់គ្រង និងអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធឌីជីថលដើម្បីអញ្ជើញវិស្វករចិនមកធ្វើបទបង្ហាញបន្ថែមអំពីហេដ្ឋារចនាសម្ព័ន្ធឌីជីថលក្នុងមជ្ឈមណ្ឌលទិន្នន័យ
- បានអនុម័តអត្តសញ្ញាណប័ណ្ណមន្ត្រីរាជការស៊ីវិលចំនួន ២១៨នាក់/ស្ត្រី ៦២នាក់ និងបន្តពិនិត្យអត្តសញ្ញាណប័ណ្ណមន្ត្រីរាជការស៊ីវិលបាន ១៥៤ នាក់ របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានរៀបចំនិងថែរក្សាបណ្ដាញប្រព័ន្ធ និងវឌ្ឍនភាពបណ្ដាញសម្រាប់ទីស្ដីការក្រសួងឱ្យមានភាពរលូន
- ធ្វើបច្ចុប្បន្នភាពទិន្នន័យ FMIS ក្រសួងស្ថាប័នថ្នាក់ជាតិ ប្រព័ន្ធថ្មី

- កំពុងអភិវឌ្ឍមុខងារប្រព័ន្ធថ្មី សម្រាប់ប្រព័ន្ធប្រាក់បៀវត្ស និងអាណត្តិបើកប្រាក់ថ្នាក់ក្រោមជាតិ
- បានបង្កើតប្រព័ន្ធដាក់ពិន្ទុឱ្យការប្រឡងគ្រូកីឡាថ្នាក់ជាតិ និងដាក់ឱ្យប្រើប្រាស់ ដោយជោគជ័យ
- បានរៀបចំឯកសារសម្រាប់ Smart Card (slide presentation and user manual)និង ឯកសារសម្រាប់ប្រព័ន្ធគ្រប់គ្រងមន្ត្រីរាជការ
- រៀបចំរបាយការណ៍ទិន្នន័យ Payroll និងគណនីធនាគារជូននាយកដ្ឋានហិរញ្ញវត្ថុនៃអគ្គលេខាធិការដ្ឋាននៃក្រសួងមុខងារសាធារណៈ
- បានកែតម្រូវឈ្មោះ(ខ្មែរ និងឡាតាំង) និងថ្ងៃខែឆ្នាំកំណើត ជូនបុគ្គលិករបស់ ក្រសួងអប់រំ យុវជន និងកីឡា ចំនួន ៨៣នាក់
- បន្តកសាងមុខងារចុះវត្តមាន មន្ត្រីប្រចាំថ្ងៃនិងកិច្ចប្រជុំនានា តាមរយៈ MCS Mobile
- បន្តសិក្សា និងកសាងប្រព័ន្ធចុះឈ្មោះប្រឡងតាមOnline
- រៀបចំរបាយការណ៍បោះពុម្ពតារាងទូទាត់បៀវត្ស អាណត្តិបើកប្រាក់ និងFMIS ចំនួន ១៥ក្រសួង-ស្ថាប័ន ក្នុងប្រព័ន្ធថ្មី HRMIS និង Payroll
- ធ្វើបច្ចុប្បន្នភាពគេហទំព័រផ្លូវការរបស់ក្រសួងមុខងារសាធារណៈ
- រៀបចំ Interface សម្រាប់មុខងារ Scan QR ចុះវត្តមាន កិច្ចប្រជុំ និង Smart Card
- បន្តធ្វើបច្ចុប្បន្នភាពកម្មវិធីឧបករណ៍ឆ្លាតវៃ (MCS Mobile)
- ធ្វើការដោះស្រាយបញ្ហានៃ MCS Mobile App មួយចំនួនដែលមានស្រាប់ ធ្វើការកែសម្រួលមុខងារ ដែលមានស្រាប់ដើម្បីដំណើរការលឿនជាងមុន
- ធ្វើការកែប្រែរូបរាង (UX/UI) MCS Mobile App ឱ្យតែកាន់តែស្រួលប្រើជាងមុនទាំងផ្នែកខាងក្នុង និងក្រៅ
- អភិវឌ្ឍមុខងារសុវត្ថិភាពតាម OTP

**១.៥ ការងារអគ្គនាយកដ្ឋានគោលនយោបាយមុខងារសាធារណៈ**

ការងារនាយកដ្ឋានគោលនយោបាយអភិវឌ្ឍវិស័យមុខងារសាធារណៈ

- បានសិក្សាទិន្នន័យមន្ត្រីរាជការត្រូវដំឡើងបៀវត្សតាមវិស័យ
- បានរៀបចំដំឡើងប្រាក់បំណាច់មុខងារមន្ត្រីរាជការស៊ីវិល មន្ត្រីនគរបាលជាតិ មន្ត្រីពន្ធនាគារក្រសួងមហាផ្ទៃ យោធិននៃកងយោធពលខេមរភូមិន្ទ សម្រាប់ឆ្នាំ២០២៤ និងដំឡើងប្រាក់ឧបត្ថម្ភប្រចាំខែចំពោះសមាជិកក្រុមប្រឹក្សា រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ មន្ត្រីភូមិ និងការិយាល័យប្រជាពលរដ្ឋរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានបញ្ចប់ការរៀបចំ សេចក្ដីព្រាងអនុក្រឹត្យ និងគោលការណ៍ ស្ដីពីការពិព័ណ៌នាមុខតំណែងក្នុងកម្រិតបច្ចេកទេស
- បានបញ្ចប់ការរៀបចំឯកសារណែនាំសម្រាប់វាយតម្លៃអង្គភាពផ្ដល់សេវាសាធារណៈគំរូកម្រិត CPA1 CPA2 និង CPA3 (សម្រាប់វិស័យសុខាភិបាល) មត្តេយ្យសិក្សា និងវិទ្យាល័យ (សម្រាប់វិស័យអប់រំ)

ការងារនាយកដ្ឋានសេវាមុខងារសាធារណៈ

- បានចូលរួមសហការរៀបចំ និងសម្របសម្រួលគណៈកម្មការបច្ចេកទេសអន្តរក្រសួងក្នុងដំណាក់កាលជ្រើសសម្រាំងចុះវាយតម្លៃនៅទីតាំងជាក់ស្ដែង
- បានចូលរួមសហការរៀបចំ និងសម្របសម្រួលកិច្ចប្រជុំរបស់គណៈកម្មការវាយតម្លៃអង្គភាពផ្ដល់សេវាសាធារណៈថ្នាក់ជាតិ (គ.វ.ជ.) ក្នុងការពិនិត្យពិភាក្សានិងវាយតម្លៃលើលទ្ធផលនៃការចុះវាយតម្លៃនៅទីតាំងជាក់ស្ដែងរបស់គណៈកម្មការបច្ចេកទេសអន្តរក្រសួង
- បានសហការរៀបចំ និងសម្របសម្រួលកម្មវិធីនៃការធ្វើបទបង្ហាញរបស់បេក្ខភាពទាំង១៥ ក្នុងដំណាក់កាលវាយតម្លៃចុងក្រោយរបស់ គ.វ.ជ.

- បានចូលរួមសហការ និងសម្របសម្រួលក្នុងការរៀបចំសេចក្តីព្រាងប្រកាសអន្តរក្រសួងចំនួន២ សេចក្តីព្រាងឯកសារណែនាំចំនួន៥ និងសេចក្តីព្រាងអនុក្រឹត្យចំនួន២
- បានរៀបចំ និងផ្ទៀងផ្ទាត់ទិន្នន័យពាក់ព័ន្ធនឹងកម្រងព័ត៌មានសេវាសាធារណៈដែលមាននៅក្នុងកម្មវិធីទូរសព្ទ (Public Service App) និងច្រកទ្វារអេឡិចត្រូនិច (Public Service Gateway) របស់ក្រសួង ស្ថាប័នចំនួន ១០។

ការងារមជ្ឈមណ្ឌលធនធានអាស៊ាន និងទំនាក់ទំនងអន្តរជាតិ

- បានរៀបចំលិខិតស្នើសុំទៅក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ស្តីពីឯកសារជំនួយស្មារតី សរុបចំនួន ៣ករណី
- បានសិក្សាស្រាវជ្រាវ ប្រមូល និងចងក្រងឯកសារ ស្តីពីវិទ្យាស្ថានបណ្តុះបណ្តាលសេវាសាធារណៈរបស់ប្រទេសសមាជិកអាស៊ាន និងអាស៊ាន+៣ (ចិន ជប៉ុន និងកូរ៉េ) និងប្រទេសពាក់ព័ន្ធ ព្រមទាំងឯកសារស្តីពីប្រព័ន្ធលាភការ និងការលើកទឹកចិត្តផ្អែកលើសមិទ្ធកម្មប្រទេសថៃ
- បានបកប្រែឯកសារស្តីពី ធាតុចូលសម្រាប់ការរៀបចំផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ២០២៤-២០២៨ របស់ក្រសួងមុខងារសាធារណៈ
- បានរៀបចំ សម្របសម្រួល និងផ្តល់ធាតុចូល/ព័ត៌មាន លើឯកសារទស្សនទាន ចំនួន ៥ករណី
- បានសម្របសម្រួលជាមួយអង្គភាពទទួលបន្ទុកគម្រោង លេខាធិការដ្ឋានអាស៊ាន និងរដ្ឋបាលជាតិមុខងារសាធារណៈ (NCSA) នៃប្រទេសចិន ដើម្បីអនុវត្តគម្រោង ASEAN Guidelines on Public Service Delivery ដំណាក់កាលទី២ គឺការធ្វើទស្សនកិច្ចសិក្សាទៅកាន់ប្រទេសចិន (Study Visit to China) ដែលនឹងប្រព្រឹត្តទៅនៅខែមីនា ឆ្នាំ២០២៤ ក្រោមផែនការការងារ ACCSM+3 ២០២១-២០២៥
- បានសម្របសម្រួលជាមួយអង្គភាពទទួលបន្ទុកគម្រោង និងលេខាធិការដ្ឋានអាស៊ាន ដើម្បីអនុវត្តគម្រោងសិក្ខាសាលាស្តីពី Digitalization in Public Administration របស់ក្រសួងមុខងារសាធារណៈកម្ពុជា ដែលស្ថិតក្រោម ផែនការការងារ ACCSM+3 ២០២១-២០២៥
- បានចូលរួមក្នុងការគាំទ្រដល់ការងារកែទម្រង់រដ្ឋបាលសាធារណៈ និងការងារពាក់ព័ន្ធផ្សេងៗ

## ១.៦ ការងារអគ្គលេខាធិការដ្ឋានគណៈកម្មាធិការកែទម្រង់រដ្ឋបាលសាធារណៈ (អ.គ.ក.ស.)

ការងារបរិវត្តកម្មសេវាសាធារណៈ និងនវានុវត្តន៍

- បានប្រមូលចងក្រងកម្រងសេវាសាធារណៈរបស់ក្រសួង ស្ថាប័នថ្នាក់ជាតិ បានចំនួន៥ក្រសួង ស្ថាប័ន(១. ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ២.ក្រសួងមហាផ្ទៃ ៣.ក្រសួងទេសចរណ៍ ៤.ក្រសួងពាណិជ្ជកម្ម និង៥.ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍)
- បានប្រមូលចងក្រងឯកសារគោលនយោបាយសេវាសាធារណៈ និងឯកសារទស្សនទាននៃការបង្កើតការិយាល័យច្រកចេញចូលតែមួយ

ការងារលើកកម្ពស់ឧត្តមភាពសេវាសាធារណៈ

- បានរៀបចំគម្រោងសិក្សាអំពីទស្សនាទាន និងបទពិសោធនៃការរៀបចំនិងការអនុវត្តនិយាមប្រតិបត្តិនៃអង្គភាព និងមន្ត្រីផ្តល់សេវាជួរមុខ
- បានសម្របសម្រួលការអនុវត្តការវាយតម្លៃ និងការទទួលស្គាល់អង្គភាពផ្តល់សេវាសាធារណៈគំរូក្នុងវិស័យអប់រំ និងវិស័យសុខាភិបាល នៅដំណាក់កាលពិនិត្យនិងវាយតម្លៃសម្រេចចុងក្រោយរបស់គណៈកម្មការវាយតម្លៃអង្គភាពផ្តល់សេវាសាធារណៈថ្នាក់ជាតិ
- បានរៀបចំសិក្ខាសាលាចែករំលែកបទពិសោធនៃការគ្រប់គ្រង និងការផ្តល់សេវាសាធារណៈរបស់ជ័យលាភីអង្គភាពផ្តល់សេវាសាធារណៈគំរូក្នុងវិស័យអប់រំ និងវិស័យសុខាភិបាល ឆ្នាំ២០២៣ កាលពីថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤

- បានរៀបចំពិធីប្រកាសជ័យលាភីអង្គភាពផ្តល់សេវាសាធារណៈ គំរូក្នុងវិស័យអប់រំនិងវិស័យសុខាភិបាលឆ្នាំ២០២៣ និងប្រកាសដាក់ឱ្យអនុវត្តសម្រាប់ឆ្នាំ២០២៤ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់សម្តេចមហាបវរធិបតី **ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា កាលពីថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០២៤
- បានសម្របសម្រួលរៀបចំនិងដាក់ចេញនូវប្រកាសអន្តរក្រសួងស្តីពីការវាយតម្លៃ និងការទទួលស្គាល់អង្គភាពផ្តល់សេវាសាធារណៈគំរូក្នុងវិស័យអប់រំ និងប្រកាសអន្តរក្រសួងស្តីពីការវាយតម្លៃនិងការទទួលស្គាល់អង្គភាពផ្តល់សេវាសាធារណៈគំរូក្នុងវិស័យសុខាភិបាល សម្រាប់ឆ្នាំ២០២៤ ដែលផ្តោតលើវិទ្យាល័យនិងសាលាមត្តេយ្យសិក្សាសម្រាប់វិស័យអប់រំ និងមន្ទីរពេទ្យបង្អែកផ្តល់សេវាសំណុំសកម្មភាពបង្គ្រប់កម្រិត១ កម្រិត២ និងកម្រិត៣ សម្រាប់វិស័យសុខាភិបាល
- បានសហការជាមួយមជ្ឈមណ្ឌលធនធានអាស៊ាន នៃអគ្គនាយកដ្ឋានគោលនយោបាយមុខងារសាធារណៈ រៀបចំត្រៀមលក្ខណៈសម្រាប់ដំណើរការទស្សនកិច្ចសិក្សានៅសាធារណរដ្ឋប្រជាមានិតចិន ក្នុងក្របខណ្ឌ នៃការអនុវត្តគម្រោងរៀបចំឯកសារណែនាំអាស៊ានស្តីពីការផ្តល់សេវាសាធារណៈ

**ការងារគ្រប់គ្រងធនធានមនុស្ស ស្ថាប័ន និងបៀវត្ស**

- បានរៀបចំសេចក្តីព្រាងព្រះរាជក្រឹត្យលក្ខន្តិកៈដោយឡែកនៃអង្គអប់រំ
- បានរៀបចំសេចក្តីព្រាងព្រះរាជក្រឹត្យលក្ខន្តិកៈដោយឡែកនៃអង្គសុខាភិបាល
- បានរៀបចំសេចក្តីព្រាងការដំឡើងប្រាក់បៀវត្សមូលដ្ឋាន ប្រាក់បំណាច់មុខងារ ប្រាក់កម្រៃ ប្រាក់ឧបត្ថម្ភប្រចាំខែ ប្រាក់ឧបត្ថម្ភក្នុងឱកាសពិធីចូលឆ្នាំថ្មីប្រពៃណីជាតិ និងប្រាក់ឧបត្ថម្ភក្នុងឱកាសបុណ្យភ្ជុំបិណ្ឌ
- បានរៀបចំសេចក្តីព្រាងអនុក្រឹត្យស្តីពី ការរៀបចំការពិពណ៌នាមុខតំណែងសម្រាប់មន្ត្រីរាជការស៊ីវិលនៃក្រសួងស្ថាប័នថ្នាក់ជាតិ
- បានរៀបចំសេចក្តីព្រាងអនុក្រឹត្យស្តីពីការកែប្រែនិងការដំឡើងប្រាក់បំណាច់មុខងារមន្ត្រីរាជការស៊ីវិល
- បានរៀបចំសេចក្តីព្រាងអនុក្រឹត្យស្តីពីការកែប្រែនិងការដំឡើងប្រាក់បំណាច់មុខងារមន្ត្រីនគរបាលជាតិ
- បានរៀបចំសេចក្តីព្រាងអនុក្រឹត្យស្តីពីការកែប្រែនិងការដំឡើងប្រាក់បំណាច់មុខងារមន្ត្រីពន្ធនាគារ
- បានរៀបចំសេចក្តីព្រាងអនុក្រឹត្យស្តីពីការកែប្រែនិងការដំឡើងប្រាក់បំណាច់មុខងារយោធិននៃកងយោធពលខេមរភូមិន្ទ
- បានរៀបចំសេចក្តីព្រាងអនុក្រឹត្យ ស្តីពីការកែប្រែនិងការដំឡើងប្រាក់ឧបត្ថម្ភប្រចាំខែចំពោះសមាជិកក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ មន្ត្រីភូមិ និងការិយាល័យប្រជាពលរដ្ឋរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ

**ការងារកសាងកម្មវិធីជាតិកែទម្រង់រដ្ឋបាលសាធារណៈ និងត្រួតពិនិត្យនិងវាយតម្លៃ**

- បានធ្វើបច្ចុប្បន្នភាពឯកសារសេចក្តីព្រាងលើកទី៨ នៃកម្មវិធីជាតិកែទម្រង់រដ្ឋបាលសាធារណៈ ២០២៤-២០៣៥ (ដោយអនុលោមទៅតាម វិធានការគន្លឹះទាំង៣ របស់រាជរដ្ឋាភិបាល ដែលបានដាក់ចេញ រួមមាន៖ ១.ការកែលម្អប្រព័ន្ធជ្រើសរើសមន្ត្រី ២.ការលើកកម្ពស់ប្រសិទ្ធភាពការងារ និង៣.ការរៀបចំប្រព័ន្ធលើកទឹកចិត្តគាំទ្រសមិទ្ធកម្មក្នុងរដ្ឋបាលសាធារណៈ និងយុទ្ធសាស្ត្របញ្ចកោណដំណាក់កាលទី១)
- បានបន្តតាមដានត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តកម្មវិធីជាតិកែទម្រង់រដ្ឋបាលសាធារណៈ និងគោលនយោបាយមុខងារសាធារណៈ
- បានបន្តប្រមូលទិន្នន័យស្តីពីការបង្កើតក្រុមការងារកែទម្រង់រដ្ឋបាលសាធារណៈ នៅតាមក្រសួង ស្ថាប័ន និងរដ្ឋបាលរាជធានី ខេត្ត (ចំនួនសរុបទទួលបាន៖ ក្រសួង ស្ថាប័ន សរុបចំនួន ២៦ និងរដ្ឋបាលរាជធានី ខេត្ត សរុបចំនួន ២៥ បានបង្កើតក្រុមការងារកែទម្រង់រដ្ឋបាលសាធារណៈ)

- បានបន្តប្រមូលទិន្នន័យស្តីពីការអនុវត្តប្រព័ន្ធគ្រប់គ្រងវត្តមានមន្ត្រីរាជការ និងមន្ត្រីជាប់កិច្ចសន្យា នៅតាមក្រសួង ស្ថាប័ន និងរដ្ឋបាលរាជធានី ខេត្ត (ចំនួនសរុបទទួលបាន៖ ក្រសួង ស្ថាប័ន សរុបចំនួន ២៥ និងរដ្ឋបាលរាជធានី ខេត្ត សរុបចំនួន ២៥ បានផ្តល់របាយការណ៍ស្តីពីការអនុវត្តប្រព័ន្ធគ្រប់គ្រងវត្តមាន)
- បានបន្តប្រមូលទិន្នន័យស្តីពីការអនុវត្តប្រព័ន្ធលើកទឹកចិត្តមន្ត្រី នៅតាមក្រសួង ស្ថាប័ន និងរដ្ឋបាលរាជធានី ខេត្ត (ចំនួនសរុបទទួលបាន៖ ក្រសួង ស្ថាប័ន សរុបចំនួន ២០ និងរដ្ឋបាលរាជធានី ខេត្ត សរុបចំនួន ២៥ បានផ្តល់របាយការណ៍ស្តីពីការអនុវត្តប្រព័ន្ធលើកទឹកចិត្តមន្ត្រី)

ការងារសម្របសម្រួលការងារកែទម្រង់អន្តរវិស័យ

- បាននឹងកំពុងធ្វើបច្ចុប្បន្នភាពតារាងកិច្ចសហប្រតិបត្តិការ និងយន្តការទំនាក់ទំនងជាមួយដៃគូអភិវឌ្ឍន៍ ដែលគាំទ្រដល់ការងារកែទម្រង់រដ្ឋបាលសាធារណៈ និងវិស័យមុខងារសាធារណៈ
- បានធ្វើកិច្ចសហប្រតិបត្តិការជាមួយធនាគារពិភពលោក (World Bank) គាំទ្រដល់ការអនុវត្តវិធានការគន្លឹះរបស់រាជរដ្ឋាភិបាល
- បានរៀបចំរបាយការណ៍វឌ្ឍនភាពនៃការអនុវត្តការងារកែទម្រង់ ៣បូក១ នៃឯកសារចក្ខុវិស័យ និងយុទ្ធសាស្ត្រស្តីពីសុខដុមនីយកម្មការកែទម្រង់ ៣បូក១ សម្រាប់ឆ្នាំ២០២៣ ដែលទទួលបន្ទុកដោយការដ្ឋានកែទម្រង់រដ្ឋបាលសាធារណៈ និងក្រសួងមុខងារសាធារណៈ
- បានរៀបចំផែនការសុខដុមនីយកម្មការកែទម្រង់ ៣បូក១ សម្រាប់ឆ្នាំ២០២៤
- បានរៀបចំរបាយការណ៍ស្រាវជ្រាវវឌ្ឍនភាពនៃការអនុវត្តការងារកែទម្រង់ ៣បូក១ សម្រាប់ត្រីមាសទី៤ ឆ្នាំ២០២៣
- បានរៀបចំផែនការសកម្មភាព និងសូចនាករនៃក្របខណ្ឌគោលនយោបាយជាតិផលិតភាពសេដ្ឋកិច្ច ២០២២-២០៣៥ ដែលទទួលបន្ទុកដោយក្រសួងមុខងារសាធារណៈ
- បាននឹងកំពុងរៀបចំរបាយការណ៍ស្រាវជ្រាវស្តីពីវឌ្ឍនភាពនៃកំណែទម្រង់វិស័យអប់រំ និងសុខាភិបាលសម្រាប់ត្រីមាសទី១ ឆ្នាំ២០២៤
- បាននឹងកំពុងរៀបចំព្រឹត្តិបត្រព័ត៌មានកែទម្រង់រដ្ឋបាលសាធារណៈ

**១.៧ ការងារក្រុមការងារយេនឌ័រ**

- បានរៀបចំលិខិតស្នើសុំទិន្នន័យបែងចែកតាមភេទ និងតាមមុខតំណែងប្រចាំឆ្នាំ ទៅគ្រប់ក្រសួង ស្ថាប័ន និងរដ្ឋបាលរាជធានី ខេត្ត

## ២. ការលើកកម្ពស់សមត្ថភាពធនធានមនុស្ស និង ការពង្រឹងប្រសិទ្ធភាពនៃការអនុវត្តការងារ

ការងារមជ្ឈមណ្ឌលធនធានអាស៊ាន និងទំនាក់ទំនងអន្តរជាតិ

- បានរៀបចំ និងសម្របសម្រួលចាត់បញ្ជូនមន្ត្រី ចំនួន ២វគ្គ សរុប ០៣នាក់/ស្ត្រី ២នាក់ ចូលរួមវគ្គបណ្តុះបណ្តាលតាមអនឡាញ

ការបណ្តុះបណ្តាលដំបូង (សិស្សមន្ត្រី)

- សិស្សមន្ត្រីជាន់ខ្ពស់ជំនាន់ទី១២ មានចំនួន ៩២នាក់/ស្ត្រី ៣១នាក់ ដែលត្រូវបានបែងចែកជា៣ជំនាញរួមមាន រដ្ឋបាលសាធារណៈ សេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងទំនាក់ទំនងអន្តរជាតិ (បានសិក្សារួមលើមុខវិជ្ជាអាទិភាពមានចំនួន ១៩មុខវិជ្ជា និងសិក្សាលើមុខវិជ្ជាជំនាញ ១២មុខវិជ្ជា និងបានចុះកម្មសិក្សានៅតាមក្រសួងស្ថាប័ន ឬរដ្ឋបាលថ្នាក់ក្រោមជាតិ) បានបញ្ចប់ការបណ្តុះបណ្តាលដោយជោគជ័យតាមការរំពឹងទុក និងកំពុងរង់ចាំការបែងចែកកន្លែងត្រូវបម្រើការងារ។
- សិស្សមន្ត្រីក្រមការជំនាន់ទី១០ មានចំនួន ១១៥នាក់/ស្ត្រី៣៨នាក់ (បានសិក្សាចំនួន ២០មុខវិជ្ជា និងបានចុះកម្មសិក្សាតាមក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិ) បានបញ្ចប់ការបណ្តុះបណ្តាលដោយជោគជ័យតាមការរំពឹងទុក និងកំពុងរង់ចាំការបែងចែកកន្លែងត្រូវបម្រើការងារ។

- សិស្សមន្ត្រីគ្រប់គ្រងរដ្ឋបាលក្របខណ្ឌថ្មីឆ្នាំ២០២១៖ មានចំនួន ៧២៨នាក់ ស្ត្រីចំនួន ២៩៥នាក់ និងសិស្សក្រមការមានចំនួន ៨៦នាក់ ស្ត្រីចំនួន ៤៦នាក់ ទទួលបានជោគជ័យជាស្ថាពរចំនួន៧១៣នាក់/ស្ត្រី២៩១នាក់ និងសិស្សក្រមការចំនួន៥៩នាក់/ស្ត្រី២៨នាក់ បានបញ្ចប់ការបណ្តុះបណ្តាល។ សាលាបានធ្វើលិខិតចាត់បញ្ជូនវគ្គទី២ ដែលបានបញ្ចប់ការបណ្តុះបណ្តាលទៅក្រសួងស្ថាប័នដើមវិញ។
- សិស្សមន្ត្រីគ្រប់គ្រងរដ្ឋបាលក្របខណ្ឌថ្មីឆ្នាំ២០២២ មានចំនួនសរុប ៥៣៩នាក់/ស្ត្រី ២១៤នាក់ និងសិស្សក្រមការ ៧៩នាក់/ស្ត្រី៣០នាក់ ទទួលបានជោគជ័យជាស្ថាពរចំនួន ៥៣១នាក់/ស្ត្រី៣០៩នាក់ និងសិស្សក្រមការចំនួន៧៩នាក់/ស្ត្រី ៣០នាក់ បានបញ្ចប់ការបណ្តុះបណ្តាល។ សាលាបានធ្វើលិខិតចាត់បញ្ជូនវគ្គទី២ ដែលបានបញ្ចប់ការបណ្តុះបណ្តាលទៅក្រសួងស្ថាប័នដើមវិញ។

**ការបណ្តុះបណ្តាលជំនាញ (រយៈពេលខ្លី)**

- បានរៀបចំរបាយការណ៍ និងទិន្នន័យសិក្ខាកាមជាថ្នាក់ដឹកនាំ និងមន្ត្រីរាជការនៃមន្ទីរមុខងារសាធារណៈ ដើម្បីពិនិត្យផ្ទៀងផ្ទាត់ ត្រៀមបោះពុម្ពវិញ្ញាបនបត្រ វគ្គទី១។
- បានកំពុងរៀបចំសេចក្តីសម្រេចក្រុមការងារទី៥ដែលទទួលបន្ទុកវគ្គបណ្តុះបណ្តាលវគ្គខ្លី ឆ្នាំ២០២៤ និងគោលការណ៍បណ្តុះបណ្តាលនៅសាលាភូមិន្ទរដ្ឋបាល ដោយការបណ្តុះបណ្តាលនេះផ្តោតលើ៥មុខវិជ្ជា រួមមាន (១)ការគ្រប់គ្រងធនធានមនុស្សក្នុងរដ្ឋបាលសាធារណៈ (២)ការគ្រប់គ្រង និងអភិវឌ្ឍស្ថាប័ន (៣)ការគ្រប់គ្រងយុទ្ធសាស្ត្រ (៤)ការរៀបចំគោលនយោបាយសាធារណៈ និង (៥)ភាពជាអ្នកដឹកនាំ
- បានរៀបចំការបណ្តុះបណ្តាលរយៈពេលខ្លី ដល់សិក្ខាកាមជំនាញរដ្ឋបាលសាធារណៈ វគ្គទី១០ ឆ្នាំ២០២៤ ។

**ការងារទំនាក់ទំនងជាតិ និងអន្តរជាតិ**

- តំណាងសាលាបានចូលរួមកិច្ចប្រជុំពិភាក្សាការងារភាសាបារាំង និងការប្រារព្ធពិធីបុណ្យហ្វ្រង់កូហ្វូនី ក្រោមអធិបតីភាព ឯកឧត្តមបណ្ឌិតសភាចារ្យ **ហង់ជួន ណារ៉ុន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា នៅថ្ងៃទី០៧ ខែកុម្ភៈ ឆ្នាំ២០២៤ នៅទីស្តីការក្រសួង អប់រំ យុវជន និងកីឡា។
- សាលាបានរៀបចំកិច្ចប្រជុំក្រុមការងារសិក្ខាសាលាអន្តរជាតិបារាំងខ្មែរដែលគ្រោងរៀបចំនៅថ្ងៃទី១៥ ខែមីនា ឆ្នាំ២០២៤ នៅសាលាភូមិន្ទរដ្ឋបាល ដោយការប្រជុំនេះមានចំនួន ២ដង ផ្តោតសំខាន់លើការពិភាក្សាក្នុងការបែងចែកភារកិច្ចក្រុមការងារ ការតាមដានការងារ និងការរៀបចំឯកសារភ្ជាប់កម្មវិធីសិក្ខាសាលា និងលិខិតអញ្ជើញ។

## ២.១. កិច្ចការវិធានការគន្លឹះទី១ - ការកែលម្អប្រព័ន្ធជ្រើសរើសមន្ត្រី

- បានដាក់ឆ្លង សេចក្តីព្រាងអនុក្រឹត្យស្តីពីការដាក់ឱ្យអនុវត្តនិយាមនីតិវិធីប្រតិបត្តិសម្រាប់ការប្រឡងប្រជែងជ្រើសរើសមន្ត្រីរាជការស៊ីវិល និងនិយាមនីតិវិធីប្រតិបត្តិសម្រាប់ការប្រឡងប្រជែងជ្រើសរើសមន្ត្រីរាជការស៊ីវិល ក្នុងកិច្ចប្រជុំលេខាធិការដ្ឋាននៃ គ.រ.រ. ក្រោមការដឹកនាំដ៏ខ្ពង់ខ្ពស់របស់ ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ
- បានបន្តប្រមូលធាតុចូល និងរៀបចំសេចក្តីព្រាងឯកសារទស្សនាទាន ស្តីពីការប្រឡងជ្រើសរើស និងប្រើប្រាស់មន្ត្រីបច្ចេកទេសសុខាភិបាល

## ២.២. កិច្ចការវិធានការគន្លឹះទី២ - ការពង្រឹងសមត្ថភាពនិងសមិទ្ធកម្មស្ថាប័ន

- បានរៀបចំសេចក្តីព្រាងគម្រោង ចំនួន ២ គឺ៖ (១)សេចក្តីព្រាងគម្រោងស្តីពីការពិនិត្យឡើងវិញ ការវិភាគមុខងារ និងរចនាសម្ព័ន្ធរបស់ក្រសួង ស្ថាប័នថ្នាក់ជាតិ និង(២)សេចក្តីព្រាងគម្រោងស្តីពីការធ្វើបច្ចុប្បន្នភាពទិន្នន័យមន្ត្រីរាជការស៊ីវិលក្រសួង ស្ថាប័នថ្នាក់ជាតិ
- បាននឹងកំពុងរៀបចំសេចក្តីព្រាងសេចក្តីសម្រេច ស្តីពីការបង្កើតគណៈកម្មការដឹកនាំការពិនិត្យឡើងវិញ ការវិភាគមុខងារ និងរចនាសម្ព័ន្ធរបស់ក្រសួង ស្ថាប័នថ្នាក់ជាតិ

- បាននិងកំពុងរៀបចំសេចក្តីព្រាងសេចក្តីជូនដំណឹងស្តីពីការចាត់បញ្ជូនមន្ត្រីនៃក្រសួង ស្ថាប័នថ្នាក់ជាតិ ចូលរួមធ្វើបច្ចុប្បន្នភាពទិន្នន័យមន្ត្រីរាជការស៊ីវិល និងចូលរួមវគ្គបណ្តុះបណ្តាល
- បានរៀបចំសេចក្តីព្រាងក្រមសីលធម៌មន្ត្រីរាជការស៊ីវិល

**២.៣. កិច្ចការវិធានការគន្លឹះទី៣ - ការកែលម្អប្រព័ន្ធលើកទឹកចិត្តគាំទ្រសមិទ្ធកម្ម**

- បានរៀបចំសេចក្តីព្រាងឯកសារទស្សនទាន ស្តីពីប្រព័ន្ធលើកទឹកចិត្តគាំទ្រសមិទ្ធកម្មរបស់ក្រសួងមុខងារសាធារណៈ។

## ៣. ការលើកកម្ពស់ និង ការពង្រឹងភាពស្អាតស្អំនៅក្នុងរដ្ឋបាលសាធារណៈ

### ៣.១ ការងារអគ្គាធិការដ្ឋាន

- បានពិនិត្យ ស្រាវជ្រាវ និងបន្តតាមដានលើករណីបណ្តឹងតវ៉ាចំនួន២ ករណី៖
  - បានបង្វែរសំណុំរឿងលើករណីសំណើសុំពិនិត្យការដកហូតតួនាទី ភារកិច្ចពីប្រធានការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាលស្រុកបូទុមសាគរ ទៅបម្រើការងារជាមន្ត្រីនៅសាលាខេត្តកោះកុង ទៅឱ្យរដ្ឋបាលខេត្តកោះកុង ដើម្បីដោះស្រាយ
  - បាននឹងកំពុងរៀបចំលិខិតបង្វែរសំណុំរឿងសុំកិច្ចអន្តរាគមន៍លើករណីការដាក់វិន័យ និងដកហូតមុខតំណែង ពីប្រធានការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និង ភូមិបាល មកជាអនុប្រធានការិយាល័យគ្រប់គ្រងធនធានមនុស្ស ក្រុងអរិយក្សត្រ ខេត្តកណ្តាល។
- បានរៀបចំវគ្គបណ្តុះបណ្តាលចែករំលែកបទពិសោធន៍ការងារពាក់ព័ន្ធ នឹងការចុះធ្វើអធិការកិច្ចមុខងារសាធារណៈជូនដល់ថ្នាក់ដឹកនាំ និងមន្ត្រីរាជការទាំងអស់នៃអគ្គាធិការដ្ឋាន ចំនួន១ លើក
- បានសិក្សាស្រាវជ្រាវឯកសារ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធការងារអធិការកិច្ច នៅក្នុងប្រទេស(ក្រសួងបរិស្ថាន ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ) និងនៅក្រៅប្រទេស (ចិន ឡាវ ជប៉ុន វៀតណាម)។

ការងារនាយកដ្ឋានសវនកម្មផ្ទៃក្នុង

- បានរៀបចំសំណើសុំគោលការណ៍អនុញ្ញាតដាក់ឱ្យអនុវត្តផែនការសវនកម្មផ្ទៃក្នុងឆ្នាំ២០២៤
- បានធ្វើសវនកម្មតាមការចង្អុលបង្ហាញរបស់ថ្នាក់ដឹកនាំក្រសួងនៅមន្ទីរមុខងារសាធារណៈនាថ្ងៃទី១៤-១៦ ខែកុម្ភៈ ឆ្នាំ២០២៤ និងរៀបចំរបាយការណ៍លទ្ធផលសង្ខេបជូនឯកឧត្តមរដ្ឋមន្ត្រី
- រៀបចំវគ្គបណ្តុះបណ្តាលស្តីពី "នីតិវិធីសវនកម្មលើរបាយការណ៍ហិរញ្ញវត្ថុ" ដើម្បីពង្រឹងសមត្ថភាពមន្ត្រីរាជការនៃនាយកដ្ឋានសវនកម្មផ្ទៃក្នុង

## ៤.បញ្ហាប្រឈម

- ដោយសារតែទិន្នន័យ និងប្រព័ន្ធគ្រប់គ្រងប្រាក់បៀវត្ស កំពុងស្ថិតក្រោមការគ្រប់គ្រង និងកែលម្អប្រព័ន្ធដោយអគ្គនាយកដ្ឋានគ្រប់គ្រងប្រព័ន្ធឌីជីថល ដូច្នេះការងារជំនាញនៅអគ្គនាយកដ្ឋានគ្រប់គ្រងមុខងារសាធារណៈមានភាពយឺតយ៉ាវ ជាពិសេសការផ្តល់ព័ត៌មានគ្រឡប់ជូនថ្នាក់ដឹកនាំមិនបានទាន់ពេលវេលា
- សាលបណ្ណសារដ្ឋានតូចចង្អៀត
- ការយល់ដឹងពាក់ព័ន្ធនឹងការងារអធិការកិច្ចវិស័យមុខងារសាធារណៈនៅក្រសួង ស្ថាប័ន ថ្នាក់ជាតិ និង ថ្នាក់ក្រោមជាតិ នៅមានកម្រិត ទាមទារឱ្យមានផ្សព្វផ្សាយបន្ថែម
- លិខិតបទដ្ឋានគតិយុត្តគាំទ្រដល់ការងារអធិការកិច្ចពាក់ព័ន្ធនឹងវិស័យមុខងារសាធារណៈ និងការដោះស្រាយទំនាស់ពាក់ព័ន្ធនឹងកិច្ចការមុខងារសាធារណៈ ពុំទាន់គ្រប់គ្រាន់សម្រាប់អនុវត្តការងារ អធិការកិច្ចក្នុងស្ថានភាពបច្ចុប្បន្នទាមទារឱ្យមានការកសាងលិខិតបទដ្ឋានគតិយុត្តបន្ថែម

- ម៉ាស៊ីនមេ (Server) និងម៉ាស៊ីនកូន (Client) ភាគច្រើនមិនមានអាជ្ញាបណ្ណត្រឹមត្រូវ (crack software) និងមិនមានកម្មវិធីការពារ ឧទាហរណ៍ កម្មវិធីតាមដាននឹងឆ្លើយតប (Endpoint Detection and Response), កម្មវិធីកំចាត់មេរោគ (Antivirus)
- ស្នើសុំទិញឧបករណ៍និងកម្មវិធីក្នុងការធ្វើកោសល្យវិច័យ ស្វែងរកចំណុចខ្សោយ និងពិនិត្យចរាចរទិន្នន័យ ឬការវាយប្រហារ។

## ៥. ទិសដៅអនុវត្តបន្ត

- **រៀបចំនិងដាក់ឱ្យអនុវត្តផែនការសកម្មភាព នៃវិធានការគន្លឹះក្នុងការកែទម្រង់រដ្ឋបាលសាធារណៈ របស់រាជរដ្ឋាភិបាល និងកម្មវិធីជាតិកែទម្រង់រដ្ឋបាលសាធារណៈ ២០២៤-២០៣៥**
- ត្រៀមរៀបចំផែនការប្រតិបត្តិប្រចាំឆ្នាំ២០២៥ (AOP-2025) របស់ក្រសួងមុខងារសាធារណៈ
- តាមដានការអនុវត្តផែនការសវនកម្មប្រចាំឆ្នាំ២០២៤
- បន្តពង្រឹងគាំពារ ប្រឹក្សា ដោះស្រាយ និង សហការជាមួយក្រសួង ស្ថាប័ន ពាក់ព័ន្ធនឹងការគ្រប់គ្រងមុខងារសាធារណៈ
- បន្តសហការ និងរៀបចំការប្រឡងប្រជែងក្រសួងស្ថាប័នចំនួន០៥ រួមមាន (១) អង្គភាពប្រឆាំងអំពើពុករលួយ (២) ក្រសួងសាធារណការ និងដឹកជញ្ជូន (៣) ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ (៤) ក្រសួងអប់រំ យុវជន និងកីឡា និង (៥) ក្រសួងអភិវឌ្ឍន៍ជនបទ
- បន្តពិនិត្យសំណើសុំរបស់ក្រសួង ស្ថាប័នលើការងារ (១) ឡើងថ្នាក់ចំនួន១៥លិខិត (២) និយ័តកម្មថ្នាក់ និងឋានន្តរស័ក្តិ០១លិខិត (៣) តាំងស៊ប់ចំនួន០១លិខិត (៤) ស្ថិតនៅក្រៅក្របខណ្ឌដើមចំនួន០លិខិត (៥) បោះពុម្ពអត្តសញ្ញាណប័ណ្ណមន្ត្រីរាជការចំនួន០៤លិខិត (៦) ការងារតែងតាំងចំនួន១៩លិខិត (៨) ផ្ទេរក្របខណ្ឌចំនួន០៦លិខិត (៨) សលាកបត្រព័ត៌មានចំនួន១០លិខិត
- បន្តពិនិត្យ និងធ្វើបច្ចុប្បន្នភាព លើសំណុំឯកសារនៃការផ្លាស់ប្តូរស្ថានភាពរដ្ឋបាល និងគ្រួសាររបស់មន្ត្រីរាជការស៊ីវិល ដើម្បីបោះពុម្ពអាណាត្តិបើកប្រាក់ប្រចាំខែមីនា ឆ្នាំ២០២៤
- ត្រៀមធ្វើបច្ចុប្បន្នភាពទីប្រឹក្សា ជំនួយការចំនួន៣១ ក្រសួង ស្ថាប័ន សម្រាប់ខែមីនា
- បន្តជំរុញកិច្ចដំណើរការនៃការផ្ទេរបុគ្គលិកអប់រំទៅរដ្ឋបាលក្រុង ស្រុក ខណ្ឌ តាមរយៈការផ្តល់ជាតុចូល ដើម្បីកសាងឯកសារទស្សនទានប្រព័ន្ធគ្រប់គ្រងគ្រូបង្រៀន និងបុគ្គលិកសុខាភិបាល
- សិក្សា និងកសាងកម្រងសេវា ស្តីពីការវិវត្តអាជីពមន្ត្រីរាជការស៊ីវិល ដែលស្ថិតក្រោមដែនសមត្ថកិច្ចរបស់អគ្គនាយកដ្ឋានគ្រប់គ្រងមុខងារសាធារណៈ ដើម្បីកំណត់ពេលវេលាជាក់លាក់មួយ
- សិក្សា និងរៀបចំនិយាមប្រតិបត្តិ ដើម្បីបង្កើនប្រសិទ្ធភាពការងារ និងគាំទ្រដល់ការអនុវត្តសេវា ស្តីពីការវិវត្តអាជីពរបស់មន្ត្រីរាជការស៊ីវិល និងអភិវឌ្ឍន៍សមត្ថភាពរបស់អគ្គនាយកដ្ឋាន
- រៀបចំស្នើសុំគោលការណ៍ពីថ្នាក់ដឹកនាំក្រសួង ដើម្បីផ្តល់សុពលភាពលើសលាកបត្រ ១៩,៧៣២សន្លឹក ដែលពុំទាន់ចុះហត្ថលេខារបស់ថ្នាក់ដឹកនាំក្រសួងមុខងារសាធារណៈនៅឡើយ។
- រៀបចំកិច្ចប្រជុំ ដើម្បីពិនិត្យ និងពិគ្រោះយោបល់លើឯកសារទស្សនទានស្តីពីការកសាងក្របខណ្ឌសមត្ថភាពភាពជាអ្នកដឹកនាំសម្រាប់មន្ត្រីរាជការគ្រប់គ្រងកម្រិតនាយកដ្ឋាន នៃក្រសួង ស្ថាប័ន
- សិក្សាស្រាវជ្រាវអំពីប្រព័ន្ធគ្រប់គ្រងបុគ្គលិករបស់ប្រទេសកូរ៉េ ជប៉ុន និងសិង្ហបុរី
- សិក្សាពីប្រព័ន្ធបៀវត្សរបស់ប្រទេសជប៉ុន និងធ្វើបច្ចុប្បន្នភាពលើឯកសារសិក្សាស្រាវជ្រាវស្តីពីប្រព័ន្ធ បៀវត្ស និងលាភការនៃប្រទេសសិង្ហបុរី និងហ្វីលីពីន

- បន្តកិច្ចសហការរៀបចំ និងសម្របសម្រួលក្នុងដំណើរការនៃការវាយតម្លៃនិងទទួលស្គាល់អង្គភាពផ្តល់សេវាសាធារណៈគំរូក្នុងវិស័យអប់រំនិងវិស័យសុខាភិបាលឆ្នាំ២០២៤ ដែលមានវិទ្យាល័យ សាលាមត្តេយ្យសិក្សា CPA1 CPA2 និងCPA3
- រៀបចំវគ្គបណ្តុះបណ្តាលស្តីពីការកែលម្អគុណភាពនៃការផ្តល់សេវាសាធារណៈដល់ក្រសួង ស្ថាប័នថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ
- ប្រមូលនិងរៀបចំចងក្រងទិន្នន័យពាក់ព័ន្ធការផ្តល់សេវារបស់ក្រសួង ស្ថាប័នថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ដើម្បីធ្វើបច្ចុប្បន្នភាពកម្រងព័ត៌មានសេវាសាធារណៈ
- សម្របសម្រួលជាមួយលេខាធិការដ្ឋានអាស៊ាន ពាក់ព័ន្ធនឹងការរៀបចំ និងជំរុញការអនុវត្តគម្រោងនានារបស់កម្ពុជាដែលស្ថិតនៅក្រោមផែនការការងារ ACCSM និង ACCSM+3 ២០២១-២០២៥
- បន្តសហការការងារជាមួយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ លើកម្មវិធី CamDigiKey និង OTP
- បណ្តុះបណ្តាលប្រព័ន្ធបម្រែបម្រួលស្ថានភាពរដ្ឋបាល និងគ្រួសារមន្ត្រីរាជការ, ប្រព័ន្ធគ្រប់គ្រងអត្តសញ្ញាណប័ណ្ណមន្ត្រីរាជការស៊ីវិល (Smart Card) ប្រព័ន្ធថ្មីHRMIS និងPayroll ដល់អគ្គនាយកដ្ឋានគ្រប់គ្រងមុខងារសាធារណៈនៃក្រសួងមុខងារសាធារណៈ
- រៀបចំសិក្សាក្នុងការបង្កើត DataWarehouse ដែលប្រមូលផ្តុំទិន្នន័យចាស់ៗកន្លងមកសម្រាប់ការងារវិភាគទិន្នន័យ
- ធ្វើការសាកល្បងប្រើប្រាស់ប្រព័ន្ធថ្មីសម្រាប់ការធ្វើបម្រែបម្រួលស្ថានភាពរដ្ឋបាលនិងគ្រួសារមន្ត្រីរាជការ ប្រចាំខែសម្រាប់រៀបចំតារាងទូទាត់បៀវត្សលើប្រព័ន្ធថ្មី
- បន្តសិក្សានឹងរៀបអំពីស្តង់ដាសុវត្ថិភាព សម្រាប់យកមកប្រើប្រាស់ជាស្តង់ដា ក្នុងការកំណត់សុវត្ថិភាពលើការអភិវឌ្ឍប្រព័ន្ធឌីជីថល និងការគ្រប់គ្រងហេដ្ឋារចនាសម្ព័ន្ធឌីជីថល
- បន្តសហការជាមួយនាយកដ្ឋានគ្រប់គ្រង និងអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធឌីជីថល និងនាយកដ្ឋានបរិវត្តកម្មឌីជីថលក្នុងការបង្កើតម៉ាស៊ីនមេសម្រាប់បម្រុងទុក (Backup Servers) និងធ្វើការសាកល្បងស្តារទិន្ន័យឡើងវិញដើម្បីឱ្យប្រាកដថា ការបម្រុងទុក និងស្តារឡើងវិញដំណើរការដោយជោគជ័យ
- បន្តគ្រប់គ្រងលើប្រព័ន្ធ VPN និង ធ្វើការបង្កើតឈ្មោះអ្នកប្រើប្រាស់តាមការស្នើសុំរបស់នាយកដ្ឋាននានាដើម្បីជានាអាចធ្វើការពីចម្ងាយចូលទៅប្រព័ន្ធ និងឧបករណ៍ផ្សេងៗបានដោយសុវត្ថិភាព
- បន្តត្រួតពិនិត្យចរាចរណ៍ទិន្នន័យ ដែលមិនប្រក្រតីឬការវាយប្រហារមកលើហេដ្ឋារចនាសម្ព័ន្ធឌីជីថល
- បន្តសិក្សា និងបង្កើតការបណ្តុះបណ្តាលឬផ្សព្វផ្សាយការយល់ដឹងអំពីសុវត្ថិភាពខ្លីៗ ទៅដល់មន្ត្រីរាជការក្នុងក្រសួង
- បន្តសហការជាមួយនាយកដ្ឋានគ្រប់គ្រង និងអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធឌីជីថល និងនាយកដ្ឋានបរិវត្តកម្មឌីជីថលក្នុងការបង្កើតម៉ាស៊ីនមេ និងរៀបចំផែនការដើម្បីផ្លាស់ទីគេហទំព័រ របស់ក្រសួងមុខងារសាធារណៈ www.mcs.gov.kh ពីក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ មកដាក់នៅក្រសួងមុខងារសាធារណៈវិញ
- បន្តសិក្សានិងរៀបចំការធ្វើកោសល្យវិច័យ ដើម្បីស្វែងរកចំណុចខ្សោយនៅលើថ្នាលឌីជីថល និងឧបករណ៍បណ្តាញផ្សេង
- បង្កើតនិងបន្តការអភិវឌ្ឍកម្មវិធី (MCSDC) សម្រាប់គ្រប់គ្រងសលាកបត្រព័ត៌មានរបស់មន្ត្រីរាជការស៊ីវិល
- ធ្វើការសិក្សារៀបចំបណ្តាញ និងប្រព័ន្ធអ៊ីនធឺណិតក្នុងទីស្តីការក្រសួងមុខងារសាធារណៈ
- បន្តអភិវឌ្ឍមុខងារប្រព័ន្ធថ្មី សម្រាប់ប្រព័ន្ធប្រាក់បៀវត្សថ្នាក់ក្រោមជាតិ
- ចូលរួមជាមួយនាយកដ្ឋានបរិវត្តកម្ម ក្នុងការកែលម្អប្រព័ន្ធ HRMIS ដើម្បីធ្វើបច្ចុប្បន្នភាពរចនាសម្ព័ន្ធក្រសួង ស្ថាប័នរាជធានី ខេត្ត និងធ្វើបច្ចុប្បន្នភាពទិន្នន័យមន្ត្រីរាជការស៊ីវិល

- ចូលរួមជាមួយនាយកដ្ឋានបរិវត្តកម្មឌីជីថល និងនាយកដ្ឋានសុវត្ថិភាពឌីជីថល រចនានិងអភិវឌ្ឍផ្ទាំងព័ត៌មានការងារក្នុងរដ្ឋបាលសាធារណៈរបស់រាជរដ្ឋាភិបាលកម្ពុជា
- បានបន្តរៀបចំ API ក្នុងប្រព័ន្ធថ្មីសម្រាប់ធ្វើសន្ទានកម្មជាមួយប្រព័ន្ធ FMIS ចំពោះគ្រប់ក្រសួង ស្ថាប័នថ្នាក់ជាតិ
- រៀបចំប្តូរ Server និងភ្ជាប់ប្រព័ន្ធសុវត្ថិភាព SSL (Secure Sockets Layer) សម្រាប់គេហទំព័រក្រសួង របស់ក្រសួងមុខងារសាធារណៈ
- ស្នើសុំគោលការណ៍ដើម្បីចុះធ្វើអធិការកិច្ចវិស័យមុខងារសាធារណៈនៅក្រសួង ស្ថាប័នថ្នាក់ជាតិ រាជធានី ខេត្ត ក្រុង ស្រុក និងឃុំ សង្កាត់ សរុបចំនួន៥
- កសាងសេចក្តីសម្រេចចំនួន៤ សម្រាប់អនុវត្តក្នុងអគ្គាធិការដ្ឋាន៖
  - សេចក្តីសម្រេចស្តីពីការបង្កើតក្រុមការងារបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋនៃអគ្គាធិការដ្ឋាន
  - សេចក្តីសម្រេចស្តីពីការបង្កើតក្រុមប្រឹក្សាវិន័យចំពោះមន្ត្រីរាជការស៊ីវិល និងមន្ត្រីជាប់កិច្ចសន្យា នៃអគ្គាធិការដ្ឋាន
  - សេចក្តីសម្រេចស្តីពីការបង្កើតក្រុមការងារសិក្សាស្រាវជ្រាវ ចងក្រង និងកសាងលិខិតបទដ្ឋានគតិយុត្ត ពាក់ព័ន្ធនឹងវិស័យមុខងារសាធារណៈ
  - សេចក្តីសម្រេចស្តីពីការបង្កើតក្រុមការងាររៀបចំរបាយការណ៍ពាក់ព័ន្ធអគ្គាធិការដ្ឋាន
- បន្តកសាងសេចក្តីព្រាងអនុក្រឹត្យស្តីពីវិធាន និងនីតិវិធីអធិការកិច្ចមុខងារសាធារណៈ
- បន្តសិក្សាស្រាវជ្រាវឯកសារ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធការងារអធិការកិច្ច នៅក្នុងប្រទេស និងនៅក្រៅប្រទេស
- ត្រៀមរៀបចំប្រារព្ធកម្មវិធីខួបលើកទី១១៣ ទិវាអន្តរជាតិនារី ៨មីនា ២០២៤ ក្រោមមូលបទ"ស្ត្រីនិងក្មេងស្រីក្នុងបរិវត្តកម្មឌីជីថល" តាមការណែនាំដ៏ខ្ពង់ខ្ពស់របស់ ឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- ត្រៀមជួបពិភាក្សាជាមួយក្រសួងកិច្ចការនារី ដើម្បីពិនិត្យឡើងវិញលើអនុស្សារណៈនៃការយោគយល់គ្នា ស្តីពីភាពជាដៃគូក្នុងការពង្រឹងសមភាពយេនឌ័រក្នុងវិស័យមុខងារសាធារណៈ រវាងក្រសួងមុខងារសាធារណៈ និងក្រសួងកិច្ចការនារី
- សិក្សាប្រមូលចងក្រងបច្ចុប្បន្នភាពទិន្នន័យពាក់ព័ន្ធនឹងកម្រងសេវាសាធារណៈរបស់ក្រសួង ស្ថាប័នថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ
- សិក្សាប្រមូលចងក្រងឯកសារ និងលិខិតបទដ្ឋានគតិយុត្តដែលពាក់ព័ន្ធនឹងការពង្រឹងការអនុវត្តយន្តការច្រកចេញចូលតែមួយរបស់ក្រសួង ស្ថាប័នថ្នាក់ជាតិ
- សិក្សាលើធាតុចូលដែលក្រុមការងារប្រមូលបានអំពីទស្សនាទាន និងបទពិសោធនៃការរៀបចំនិងការដាក់ឱ្យអនុវត្តនិយាមប្រតិបត្តិនៃអង្គភាពផ្តល់សេវាសាធារណៈជួរមុខ ដើម្បីរៀបចំឯកសារទស្សនាទាន និងឯកសារនិយាមប្រតិបត្តិដើម្បីដាក់ឱ្យអនុវត្តក្នុងរដ្ឋបាលសាធារណៈ
- សិក្សា និងជ្រើសរើសអង្គភាពដែលមានឧត្តមភាពសេវា ដើម្បីរៀបចំនិងផ្សព្វផ្សាយពីឧត្តមានុវត្តន៍សម្រាប់ជំរុញចលនាកែលម្អការផ្តល់សេវាសាធារណៈ
- ប្រជុំពិភាក្សាកំណត់ប្រធានបទ វិធីសាស្ត្រ និងសកម្មភាពសម្រាប់ការរៀបចំករណីសិក្សាស្តីពីឧត្តមានុវត្តនៃការអនុវត្តការផ្តល់សេវាសាធារណៈក្នុងវិស័យអប់រំនិងវិស័យសុខាភិបាល
- បន្តសម្របសម្រួលការអនុវត្តការវាយតម្លៃនិងការទទួលស្គាល់អង្គភាពផ្តល់សេវាសាធារណៈគំរូក្នុងវិស័យ អប់រំ និងវិស័យសុខាភិបាល
- ប្រមូលចងក្រងច្បាប់និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងការគ្រប់គ្រងមន្ត្រីរាជការក្នុងវិស័យអប់រំ និង សុខាភិបាល

- បន្តរៀបចំលើកសំណើគម្រោង (Project Proposal) សម្រាប់គម្រោងទាំង៣ របស់អនុគណៈកម្មាធិការ រួមមាន (១)ការរៀបចំព្រះរាជក្រឹត្យស្ដីពីអង្គអប់រំ (២)ការរៀបចំព្រះរាជក្រឹត្យស្ដីពីអង្គរដ្ឋបាល និង(៣)ការរៀបចំអនុក្រឹត្យស្ដីពីការពិពណ៌នាមុខតំណែងមន្ត្រីរាជការស៊ីវិលនៃក្រសួង ស្ថាប័នថ្នាក់ជាតិ
- រៀបចំលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធទៅនឹងការបណ្ដុះបណ្ដាល ការកសាងសមត្ថភាពធនធានមនុស្សក្នុងរដ្ឋបាលសាធារណៈ ក្នុងនោះផ្ដោតទៅលើ៖ ទី១.ការរៀបចំឯកសារក្របខណ្ឌទស្សនាទាននៃការបណ្ដុះបណ្ដាលមន្ត្រីសម្រាប់រយៈពេលមធ្យមនិងវែង និងទី២.ការរៀបចំក្របខណ្ឌគុណវុឌ្ឍិមន្ត្រីសម្រាប់ការបណ្ដុះបណ្ដាល
- រៀបចំការអភិវឌ្ឍសមត្ថភាពមន្ត្រីរាជការតាមរយៈ (ទី១)ការពង្រឹងភាពជាអ្នកដឹកនាំក្នុងរដ្ឋបាលសាធារណៈកម្រិតអគ្គនាយក (ទី២)ការពង្រឹងភាពជាអ្នកដឹកនាំក្នុងរដ្ឋបាលសាធារណៈកម្រិតប្រធាននាយកដ្ឋានធនធានមនុស្ស និង(ទី៣)ការរៀបចំបណ្ដាញភាពជាអ្នកដឹកនាំកម្រិតអគ្គនាយក
- រៀបចំបញ្ចប់ឯកសារសេចក្ដីព្រាងកម្មវិធីជាតិកែទម្រង់រដ្ឋបាលសាធារណៈ ២០២៤-២០៣៥
- រៀបចំសេចក្ដីព្រាងឯកសារក្របខណ្ឌលទ្ធផល (Result Framework) នៃការតាមដានត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តសកម្មភាពការងារកែទម្រង់រដ្ឋបាលសាធារណៈ
- រៀបចំរបាយការណ៍វឌ្ឍនភាពការអនុវត្តការងារកែទម្រង់រដ្ឋបាលសាធារណៈ ប្រចាំត្រីមាសទី១ ឆ្នាំ២០២៤
- រៀបចំរបាយការណ៍លទ្ធផលស្ដីពីការបូកសរុបទិន្នន័យនៃការអនុវត្តប្រព័ន្ធគ្រប់គ្រងវត្តមានមន្ត្រីរាជការ និងមន្ត្រីជាប់កិច្ចសន្យារបស់ក្រសួង ស្ថាប័ន និងរដ្ឋបាលរាជធានី ខេត្ត
- រៀបចំរបាយការណ៍លទ្ធផលស្ដីពីការបូកសរុបទិន្នន័យនៃការអនុវត្តប្រព័ន្ធលើកទឹកចិត្តមន្ត្រីរបស់ក្រសួង ស្ថាប័ន និងរដ្ឋបាលរាជធានី ខេត្ត
- បន្តតាមដានត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តកម្មវិធីជាតិកែទម្រង់រដ្ឋបាលសាធារណៈ និងគោលនយោបាយមុខងារសាធារណៈ
- តាមដាន និងត្រួតពិនិត្យការអនុវត្តការងារកែទម្រង់រដ្ឋបាលសាធារណៈរបស់ក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិ និងការអនុវត្តផែនការសកម្មភាពកែទម្រង់រដ្ឋបាលសាធារណៈរបស់អនុគណៈកម្មាធិការទាំង៤ នៃ គ.ក.ស. និងក្រុមការងារបច្ចេកទេសទាំង៣ នៃ អនុគណៈកម្មាធិការប្រតិបត្តិ នៃ គ.វ.រ.
- បូកសរុបទិន្នន័យនៃការបង្កើតក្រុមការងារកែទម្រង់រដ្ឋបាលសាធារណៈ ដែលក្រសួង ស្ថាប័ន និងរដ្ឋបាលរាជធានីខេត្ត បានផ្ញើមក អគ្គលេខាធិការដ្ឋាន គ.ក.ស.
- រៀបចំរបាយការណ៍លទ្ធផលស្ដីពីការបូកសរុបទិន្នន័យ នៃការអនុវត្តប្រព័ន្ធគ្រប់គ្រងវត្តមានមន្ត្រីរាជការរបស់ក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិ
- តាមដាន និងត្រួតពិនិត្យការអនុវត្តការងារកែទម្រង់រដ្ឋបាលសាធារណៈរបស់ក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិ និងការអនុវត្តផែនការសកម្មភាពកែទម្រង់រដ្ឋបាលសាធារណៈរបស់អនុគណៈកម្មាធិការទាំង៤ នៃ គ.ក.ស. និងក្រុមការងារបច្ចេកទេសទាំង៣ នៃអនុគណៈកម្មាធិការប្រតិបត្តិ នៃ គ.វ.រ.
- ត្រៀមរៀបចំផ្សព្វផ្សាយ ឯកសារចក្ខុវិស័យសុខដុមនីយកម្មកែទម្រង់៣បូក១ ក្នុងក្របខណ្ឌក្រសួងមុខងារសាធារណៈ
- សិក្សា និងរៀបចំយន្តការទំនាក់ទំនងជាមួយដៃគូអភិវឌ្ឍន៍ក្នុងក្របខណ្ឌការងារកែទម្រង់រដ្ឋបាសាធារណៈ
- បន្តស្រាវជ្រាវវឌ្ឍនភាពនៃការអនុវត្តការងារកែទម្រង់ ៣បូក១ សម្រាប់ត្រីមាសទី១ ឆ្នាំ២០២៤ (ការកែទម្រង់រដ្ឋបាលសាធារណៈ ការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ កំណែទម្រង់សម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ និងការកែទម្រង់ប្រព័ន្ធយុត្តិធម៌)
- បន្តសិក្សាស្រាវជ្រាវវឌ្ឍនភាពនៃការអនុវត្តការងារកែទម្រង់នៃគោលនយោបាយតាមវិស័យ (អប់រំ និងសុខាភិបាល) សម្រាប់ត្រីមាសទី១ ឆ្នាំ២០២៤

- បន្តសិក្សា និងធ្វើបច្ចុប្បន្នភាពបញ្ជីឈ្មោះដៃគូអភិវឌ្ឍន៍ ដែលជួយគាំទ្រដល់ការអនុវត្តការងារកែទម្រង់រដ្ឋបាលសាធារណៈ
- រៀបចំវគ្គបណ្តុះបណ្តាល ឬ សិក្ខាសាលាចែករំលែកបទពិសោធសម្រាប់ការអភិវឌ្ឍសមត្ថភាពរបស់ថ្នាក់ដឹកនាំ និងមន្ត្រីរាជការ លើការងារកែទម្រង់រដ្ឋបាលសាធារណៈ
- សិក្សាស្រាវជ្រាវអំពីឧត្តមានុវត្តន៍ (Best Practice) នៃកិច្ចការរដ្ឋបាលនិងបុគ្គលិកប្រកបដោយនវានុវត្តន៍ នៅតាមបណ្តាក្រសួង ស្ថាប័ន ក្នុងប្រទេស និងក្នុងតំបន់អាស៊ាន
- បន្តគាំទ្រ សម្របសម្រួល និងរៀបចំកិច្ចប្រជុំ សិក្ខាសាលា និងការងារពិធីការនានារបស់គណៈកម្មាធិការកែទម្រង់រដ្ឋបាលសាធារណៈ ក្រុមការងារបច្ចេកទេសទាំង៣ នៃអនុគណៈកម្មាធិការប្រតិបត្តិ នៃ គ.វ.រ. អនុគណៈកម្មាធិការ នៃ គ.ក.ស. និងអគ្គលេខាធិការដ្ឋាន គ.ក.ស.។

## ៦. សេចក្តីសន្និដ្ឋាន

នៅក្នុងខែកុម្ភៈ ឆ្នាំ២០២៤ ក្រសួងមុខងារសាធារណៈ បានដឹកនាំ គ្រប់គ្រង និងអភិវឌ្ឍវិស័យមុខងារសាធារណៈ ព្រមទាំងការងារកែទម្រង់រដ្ឋបាលសាធារណៈ សម្រេចបាននូវសមិទ្ធផលសំខាន់ៗ ជាច្រើនរួមមាន ការរៀបចំ និងកែលម្អរចនាសម្ព័ន្ធក្រសួង ស្ថាប័ន ការពង្រឹងការគ្រប់គ្រង ការវិវឌ្ឍអាជីពរបស់មន្ត្រីរាជការ និងការអភិវឌ្ឍធនធានមនុស្ស និងស្ថាប័ន ការកែលម្អការផ្តល់សេវាសាធារណៈ ការកែទម្រង់ប្រព័ន្ធបៀវត្ស ដើម្បីបង្កើនប្រាក់បៀវត្ស ប្រាក់ឧបត្ថម្ភ និងរបបសន្តិសុខសង្គម ព្រមទាំងការលើកកម្ពស់កិច្ចសហប្រតិបត្តិការជាមួយដៃគូអភិវឌ្ឍន៍នានា។

ផ្អែកលើទិសដៅការងារដែលបានកំណត់ ក្រសួងមុខងារសាធារណៈ នឹងប្រឹងប្រែងឱ្យអស់លទ្ធភាពដើម្បីសម្រេចបាននូវសមិទ្ធផលថ្មីៗបន្ថែមទៀត ក្នុងគោលបំណងកែលម្អវិស័យមុខងារសាធារណៈកម្ពុជាឱ្យឆ្លើយតបទៅនឹងការវិវឌ្ឍថ្មីៗនៃសង្គមជាតិ ។ ក្នុងន័យនេះរដ្ឋបាលសាធារណៈកម្ពុជានឹងត្រូវប្រែក្លាយឱ្យកាន់តែមានភាពរស់រវើក គុណភាព ភាពមានវិជ្ជាជីវៈ និងប្រសិទ្ធភាពក្នុងការបំពេញមុខងារ និងភារកិច្ចរបស់ខ្លួន ដើម្បីបម្រើប្រជាពលរដ្ឋកាន់តែប្រសើរ។

ថ្ងៃ ច័ន្ទ ៨រោច ខែ មាឃ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧
រាជធានីភ្នំពេញ ថ្ងៃទី ០៤ ខែ មីនា ឆ្នាំ២០២៤

ជ.រដ្ឋមន្ត្រី
រដ្ឋលេខាធិការប្រចាំការ

យក់ ប៊ុនណា